# របាយការណ៍

## ស្តីពី

## លទ្ធផលការងារសម្រេចបានឆ្នាំ២០២៤ និងទិសដៅការងារឆ្នាំ ២០២៥

## របស់ក្រសួងអភិវឌ្ឍន៍ជនបទ

ថ្ងៃព្រហស្បតិ៍-សុក្រ ៨-៩ រោច ខែមាឃ ឆ្នាំរោង ឆស័ក ពស ២៥៦៨

រាជធានីភ្នំពេញ ថ្ងៃទី២០-២១ ខែកុម្ភៈ ឆ្នាំ ២០២៥

### ១. សេចក្តីផ្តើម

ក្នុងរយៈពេល ២៦ ឆ្នាំចុងក្រោយបន្ទាប់ពីការសម្រេចបាននូវសន្តិភាពពេញលេញ ឯកភាពជាតិ និងឯកភាពទឹកដីទាំងស្រុងតាមរយៈនយោបាយ ឈ្នះ ឈ្នះ របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន អតីតនាយករដ្ឋមន្ត្រី** និងបច្ចុប្បន្នជា **ប្រធានព្រឹទ្ធសភា** កម្ពុជាធានាបាននូវអធិបតេយ្យជាតិ សណ្តាប់ធ្នាប់សង្គម សន្តិសុខ សុវត្ថិភាព និងស្ថិរភាពនយោបាយ ព្រមទាំងរក្សាបានយ៉ាងគត់មត់ នូវស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈ។ មិនតែប៉ុណ្ណោះ កម្ពុជាបានផ្លាស់ប្តូរមុខមាត់ថ្មីឡើងវិញ ដោយបានកសាងនូវមូលដ្ឋានគ្រឹះដ៏រឹងមាំនៃសេដ្ឋកិច្ចជាតិសម្រាប់ការអភិវឌ្ឍ និងបានលើកកម្ពស់កម្រិតជីវភាពរស់នៅរបស់ប្រជាជនទូទាំងប្រទេសតាមរយៈ ១.ការពង្រីកជាបន្តបន្ទាប់នូវពាណិជ្ជកម្មអន្តរជាតិឈរលើគោលការណ៍ពហុភាគី រួមទាំងការធ្វើពិពិធកម្មទីផ្សារ និងទំនិញ ព្រមទាំងការពង្រឹង និងពង្រីកការធ្វើសមាហរណកម្មសេដ្ឋកិច្ចចូលក្នុងតំបន់និងពិភពលោក, ២.ការជំរុញ និងការទាក់ទាញបន្ថែមនូវការវិនិយោគផ្ទាល់ពីបរទេសតាមរយៈការកែលម្អនូវបរិយាកាសធុរកិច្ចនិងការវិនិយោគ, ៣.ការពង្រឹង និងការស្តារឡើងវិញនូវហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងឡូជីស្ទីក ដូចជាផ្លូវថ្នល់ ស្ពាន ប្រឡាយទឹក និងបណ្តាញអគ្គិសនី មណ្ឌលសុខភាព និងសាលារៀន។ល។ ដើម្បីលើកកម្ពស់ការតភ្ជាប់ និងភាពប្រកួតប្រជែង, ៤.ការបន្តអភិវឌ្ឍមូលធនមនុស្សដើម្បីចូលរួមក្នុងសកម្មភាពសេដ្ឋកិច្ច និងបង្កើនផលិតភាពប្រកបដោយភាពធន់ និង៥.ការកែទម្រង់ស្ថាប័ននិងពង្រឹងអភិបាលកិច្ចល្អជាប់ជាប្រចាំ ដើម្បីបង្កើនប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈគ្រប់ប្រភេទ។

ផ្អែកលើមូលដ្ឋាននេះ ក្រោមការដឹកនាំដ៏ត្រឹមត្រូវ ស្វាហាប់ ឈ្លាសវៃ និងប៉ិនប្រសព្វ ប្រកបដោយថាមវន្តរបស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ដោយឈរលើអភិក្រម **“រក្សាសមិទ្ធផលចាស់, បង្កើតសមិទ្ធផលថ្មី”** រាជរដ្ឋាភិបាលកម្ពុជានីតិកាលទី៧នៃរដ្ឋសភា បាននិងកំពុងបន្តខិតខំដោះស្រាយបញ្ហា ការប្រឈមនានា និងជាពិសេសចាប់ឱ្យជាប់នូវ

កាលានុវត្តភាពដែលផុសឡើងក្នុងបរិការណ៍នៃការផ្លាស់ប្តូរយ៉ាងឆាប់រហ័សនៃស្ថានភាពសង្គម សេដ្ឋកិច្ចតំបន់ និងសកលលោក។ ក្នុងគោលដៅនេះ រាជរដ្ឋាភិបាលកម្ពុជានីតិកាលទី៧ នៃរដ្ឋសភា បានដាក់ចេញនូវយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ ដើម្បីកំណើន ការងារ សមធម៌ ប្រសិទ្ធភាព និងចីរភាព ដោយកំណត់យកនូវអាទិភាពគន្លឹះចំនួន ៥ រួមមាន÷ មនុស្ស ផ្លូវ ទឹក ភ្លើង និងបច្ចេកវិទ្យា ជាពិសេសបច្ចេកវិទ្យាឌីជីថល ដើម្បីឆ្លើយតបទៅនឹងបដិវត្តន៍ឧស្សាហកម្មទី៤.០ និងបរិវត្តកម្មឌីជីថលនៃសេដ្ឋកិច្ច និងសង្គមកម្ពុជា ក៏ដូចជា ដើម្បីលើកកម្ពស់ផលិតភាពសេដ្ឋកិច្ចកម្ពុជាដែលជាគ្រឹះ និងជាមធ្យោបាយដ៏សំខាន់ក្នុងការសម្រេចបាននូវចក្ខុវិស័យកម្ពុជាឆ្ពោះទៅជាប្រទេសដែលមានប្រាក់ចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងជាប្រទេស ដែលមានប្រាក់ចំណូលខ្ពស់នៅឆ្នាំ២០៥០ “**ប្រទេសអភិវឌ្ឍន៍**”។

ដើម្បីចូលរួមអនុវត្តយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ របស់រាជរដ្ឋាភិបាល នីតិកាលទី៧ ក្រសួងអភិវឌ្ឍន៍ជនបទបានកំណត់ចក្ខុវិស័យ «**កសាងតំបន់ជនបទកម្ពុជាប្រកបដោយវិបុលភាព បរិយាបន្ន នវានុវត្តន៍ ឌីជីថល និងភាពធន់ ទាំងផ្នែកសេដ្ឋកិច្ច សង្គម និងវប្បធម៌**» ដោយមានគោលបំណងចំនួន ៣ គឺ ទី១.**បង្កើនប្រាក់ចំណូលតាមគ្រួសារនៅជនបទ** ឱ្យមានជីវភាពសមរម្យ និងមានប្រាក់ចំណូលប្រកបដោយចីរភាព តាមរយៈការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្តការបង្កើត, ការបណ្តុះបណ្តាលជំនាញអាជីព, ការងារនិងមុខរបរសមស្រប ការអភិវឌ្ឍនិងអភិរក្សជនជាតិដើមភាគតិច ការបណ្តុះគំនិតនវានុវត្តន៍ ការប្រកួតប្រជែងផលិតកម្ម និងការផ្សព្វផ្សាយតាមលក្ខណៈឌីជីថល, ទី២.**បង្កើនសុខុមាលភាពគ្រួសារនៅជនបទ** ឱ្យមានសុខភាពល្អ និងរស់នៅក្នុងបរិស្ថានដែលមានអនាម័យស្អាតតាមរយៈការផ្តល់សេវាផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ ការអប់រំ ផ្សព្វផ្សាយអំពីសុខភាព និងអនាម័យ ដើម្បីគាំទ្រដល់សុខភាពប្រជាជនជនបទ និងទី៣. **ការអប់រំសីលធម៌សង្គម ដើម្បីឱ្យមានគុណធម៌ និងឱ្យក្លាយជាពលរដ្ឋល្អ** សំដៅបង្កើនសុខុដុមនីយកម្ម កាត់បន្ថយអំពើហិង្សាក្នុងគ្រួសារ និងសហគមន៍ និងការអភិវឌ្ឍភូមិគំរូដែលជាមូលដ្ឋានគ្រឹះក្នុងការពង្រឹងមូលធនមនុស្ស ប្រកបដោយថាមពល សំដៅចូលរួមអភិវឌ្ឍន៍ប្រទេសកម្ពុជាឱ្យរីកចម្រើនបានឆាប់រហ័សតាមរយៈការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជនបទ ២០២៤-២០២៨ និងបានដាក់ចេញជាយុទ្ធសាស្ត្រអាទិភាពចំនួន៤ ÷ ១- ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត និងគមនាគមន៍, ២- ការលើកកម្ពស់លក្ខខណ្ឌនៃការរស់នៅរបស់សហគមន៍ជនបទ, ៣- ធ្វើពិពិធកម្មសកម្មភាពសេដ្ឋកិច្ចជនបទ និង ៤- ការពង្រឹងសេវាគាំទ្ររដ្ឋបាល និងកិច្ចការទូទៅ។

ក្នុងនីតិកាលទី៧ នេះ ក្រសួងអភិវឌ្ឍន៍ជនបទ បានប្រែក្លាយយុទ្ធសាស្ត្រទាំង៤ ខាងលើ ដែលជាកម្មវិធីនយោបាយអាទិភាពរបស់ខ្លួន ដែលមានគោលដៅចំនួន៩ គឺ ១- កែលម្អស្ថានភាពសង្គមកិច្ច និងសេដ្ឋកិច្ច នៅតំបន់ជនបទឱ្យបានល្អប្រសើរ, ២- កាត់បន្ថយជាបណ្តើរៗនូវគម្លាត ជីវភាពរស់នៅរវាងជនបទ និងទីប្រជុំជន ដែលជំរុញមេគុណជីនីឱ្យកាន់តែល្អប្រសើរ, ៣- រៀបចំបំណិនជីវិត(ជំនាញវិជ្ជាជីវៈមូលដ្ឋាន) ដើម្បីបង្កើតឱកាសការងារ និងមុខរបរឱ្យកាន់តែប្រសើរឡើង, ៤- លើកកម្ពស់ផលិតភាពនិងបង្កើនប្រាក់ចំណូលតាមគ្រួសារ, ៥- កែលម្អប្រព័ន្ធឡជីស្ទីកនៅជនបទឱ្យកាន់តែល្អប្រសើរ និងមានភាពធន់, ៦- អភិវឌ្ឍន៍ជនបទចម្រុះថ្នាក់សហគមន៍, ៧- លើកកម្ពស់ការផ្តល់សេវាសុខុមាលភាពជូនប្រជាជនជនបទ, ៨- អភិវឌ្ឍ និងអភិរក្សជនជាតិដើមភាគតិច និង៩- អភិបាលកិច្ច និងគណនេយ្យភាពការងារ។

ក្នុងនីតិកាលទី៧ ក្រសួងអភិវឌ្ឍន៍ជនបទ សម្រេចបាននូវសូចនាករលទ្ធផលក្នុងឆ្នាំនិងសូចនាករ

លទ្ធផលចុងក្រោយជាច្រើនគួរឱ្យកត់សម្គាល់ ទោះជាស្ថិតក្នុងស្ថានភាពរងឥទ្ធិពលនៃសង្គ្រាមជាសកល និងអតិផរណានៃសេដ្ឋកិច្ចជាតិក៏ដោយ ក៏ក្រសួងបានជម្នះគ្រប់ឧបសគ្គ និងកំពុងរួមចំណែកយ៉ាងសកម្ម ក្នុងការជំរុញឱ្យមានការផ្លាស់ប្តូរជីវភាពរស់នៅរបស់ប្រជាជនជនបទឱ្យកាន់តែល្អប្រសើរឡើងប្រកប ដោយវិបុលភាព បរិយាបន្ន នវានុវត្តន៍ ឌីជីថល និងភាពធន់ ទាំងផ្នែកសេដ្ឋកិច្ច សង្គម និងវប្បធម៌ ។

## ២. សមិទ្ធផលសម្រេចបានក្នុងឆ្នាំ ២០២៤

នៅក្នុងឆ្នាំ២០២៤នេះ ក្រសួងអភិវឌ្ឍន៍ជនបទ បានខិតខំយកចិត្តទុកដាក់អនុវត្តការងារតាម ផែនការដែលបានគ្រោងទុក និងស្របតាមផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជនបទឆ្នាំ២០២៤-២០២៨ របស់ ខ្លួនប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ តាមគោលការណ៍ពង្រឹង ៧០% និងពង្រីក ៣០% ដោយសម្រេច បានលទ្ធផលក្នុងឆ្នាំគួរឱ្យកត់សម្គាល់ទាំងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត និងគមនាគមន៍ ការកែលម្អ លក្ខខណ្ឌនៃការរស់នៅរបស់សហគមន៍ជនបទ និងការធ្វើពិពិធកម្មសកម្មភាពសេដ្ឋកិច្ចជនបទ និងការពង្រឹង សេវាគាំទ្រ និងកិច្ចការទូទៅ ដែលសមិទ្ធផលទាំងអស់នេះ បាននិងកំពុងរួមចំណែករក្សាស្ថិរភាពនៃ ការលើកកម្ពស់កម្រិតជីវភាព សុខុមាលភាព គុណតម្លៃនៃជីវិតរស់នៅ និងការអប់រំសីលធម៌សង្គមរបស់ ប្រជាជនជនបទ ជាអាទិ៍ក្នុងឆ្នាំ២០២៤ ក្រសួងសម្រេចបានសមិទ្ធផលសំខាន់ៗជាសារវ័ន្ត ដូចខាងក្រោម÷

### ២.១. អភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត និងគមនាគមន៍

ហេដ្ឋារចនាសម្ព័ន្ធ និងគមនាគមន៍ដឹកជញ្ជូននៅជនបទ ពិតជាមានសារៈសំខាន់ណាស់ក្នុងការ ជំរុញដំណើរអន្តរកម្មផ្នែកសេដ្ឋកិច្ច សង្គមកិច្ច រវាងតំបន់ជនបទ និងទីប្រជុំជននៅកម្ពុជាពេលបច្ចុប្បន្ន។ វិស័យនេះ គឺជាសរសៃឈាមសេដ្ឋកិច្ចដ៏សំខាន់ក្នុងការផ្សារភ្ជាប់សកម្មភាពធុរកិច្ចផ្សេងៗក្នុងប្រទេស និងក្នុងតំបន់ឱ្យមានភាពរស់រវើក និងកាន់តែសកម្មឡើងទៀត ក្នុងការជំរុញកំណើនប្រាក់ចំណូលរបស់ ប្រជាជននៅជនបទ។ បច្ចុប្បន្ន ក្រសួងបាននិងកំពុងផ្តោតសំខាន់លើការពង្រឹងគុណភាពផ្លូវជនបទ និង សាងសង់ផ្លូវជនបទដែលធន់នឹងការប្រែប្រួលអាកាសធាតុដោយកែលម្អផ្លូវជនបទពីផ្លូវដី ផ្លូវល្បាយ ក្រួសឱ្យទៅជាផ្លូវក្រាលកៅស៊ូពីរជាន់ និងក្រាលបេតុង ដែលបានជួយសម្រួល និងផ្តល់ផលប្រយោជន៍ ជាច្រើនដល់ប្រជាជននៅជនបទ ដូចជា ងាយស្រួលក្នុងការធ្វើដំណើរ ចំណេញពេលវេលា កាត់បន្ថយ ការចំណាយក្នុងការដឹកជញ្ជូនសម្ភារ ទំនិញ ផលិតផលនានា ក៏ដូចជាកសិផលទៅកាន់ទីផ្សារ និងមាន ភាពងាយស្រួលក្នុងការទទួលបាននូវសេវាសាធារណៈផ្សេងៗ និងឱកាសបង្កើតមុខរបរដើម្បីបង្កើនប្រាក់ ចំណូលបន្ថែមក្រៅពីធ្វើស្រែចំការ។ ការស្ថាបនា ស្តារ ថែទាំ និងកែលម្អលើកកម្រិតហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត និងគមនាគមន៍ ព្រមទាំងសេវាសាធារណៈផ្សេងៗទៀត បាននិងកំពុងនាំមកនូវកំណើនសេដ្ឋកិច្ច ការងារ សមធម៌ និងប្រសិទ្ធភាព ជូនដល់ប្រជាជនគ្រប់ទិសទីនៅទូទាំងប្រទេស ជាពិសេសតំបន់ជនបទ នៃ ព្រះរាជាណាចក្រកម្ពុជា។ លើសពីនេះ ការតភ្ជាប់បណ្តាញផ្លូវជនបទមិនត្រឹមតែបានបង្កភាពងាយស្រួល លើផ្នែកគមនាគមន៍ដឹកជញ្ជូនប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបានផ្តល់អត្ថប្រយោជន៍ដល់ការលើកកម្ពស់ កម្រិតជីវភាពរស់នៅរបស់ប្រជាជនជនបទ ហើយជានិច្ចកាលតែងតែទទួលបានការគាំទ្រយ៉ាងពេញ ទំហឹងពីប្រជាពលរដ្ឋគ្រប់មជ្ឈដ្ឋាន។ ក្នុងការអនុវត្តកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ក្រសួង អភិវឌ្ឍន៍ជនបទ បានចូលរួមធ្វើប្រតិភូកម្មការងារថែទាំផ្លូវជាលក្ខណៈប្រចាំលើផ្លូវក្នុងភូមិទៅរដ្ឋបាលស្រុក

ចំនួន ១៥ស្រុក នៃខេត្តចំនួន ៣ រួមមាន ខេត្តកំពង់ស្ពឺ កំពង់ឆ្នាំង និងខេត្តត្បូងឃ្មុំ ដើម្បីអនុវត្តសាកល្បងលើការងារថែទាំផ្លូវជនបទ ។

នៅឆ្នាំ២០២៤នេះ លទ្ធផលសម្រេចពីការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត និងគមនាគមន៍ បានបង្ហាញថា ការងារស្ថាបនា ស្តារ ថែទាំ និងកែលម្អលើកកម្រិតផ្លូវជនបទសម្រេចបាន ៩៧% នៃផែនការឆ្នាំ២០២៤ ដោយក្នុងនោះថែទាំ និងជួសជុលផ្លូវជនបទដោយគាំទ្រថវិកាជាតិមាន ចំនួន ៤០៤ខ្សែ **ប្រវែង ៤ ២៧២គ.ម** ក្នុងនោះការងារថែទាំខួបលើផ្លូវក្រាលល្បាយក្រួសបានប្រវែងសរុប ៣៣៤គម., ថែទាំខួបផ្លូវក្រាលកៅស៊ូ បានប្រវែង ៦៩គម., ថែទាំខួបផ្លូវក្រាលបេតុងបានប្រវែង ០៣៨គ,.ម, សាងសង់លូមូលចំនួន ៧១កន្លែង សាងសង់លូប្រអប់ចំនួន ៣កន្លែង និងការងារថែទាំប្រចាំផ្លូវក្រាលល្បាយក្រួសប្រវែង ២ ៤៤៦ គម., ថែទាំប្រចាំផ្លូវក្រាលកៅស៊ូប្រវែង ១ ២១៣គម., បំពាក់ស្លាកចរាចរណ៍ ចំនួន ១៨៩២ស្លាក, ដាំកូនឈើអមសងខាងផ្លូវចំនួន ២៥ ៥៦៨ដើម, សាងសង់ទីទួលសុវត្ថិភាពចំនួន ១កន្លែង និងការងារជួសជុលបន្ទាន់ហេដ្ឋារចនាសម្ព័ន្ធផ្លូវជនបទដែលរងផលប៉ះពាល់ដោយសារទឹកជំនន់ ចំនួន ១១៣ ករណី ស្មើនឹងប្រវែង ២១០ គ.ម និងជួសជុលលូមូលគ្រប់ប្រភេទ បានចំនួន ២៩ កន្លែង, ជួសជុលស្ពាន បានចំនួន ៤កន្លែង ប្រវែង ៩០ម និងសាងសង់លូអ៊ុយ បានប្រវែង ១៨០ម។ សម្រាប់ការងារស្ថាបនាពង្រីកវិសាលភាព និងកែលម្អលើកកម្រិតផ្លូវជនបទ ប្រវែង ១ ៣៣០គ.ម ដែលក្នុងនោះហិរញ្ញប្បទានដោយថវិកាជាតិ ចំនួន ១៥០ខ្សែ **ប្រវែងសរុប ៣៩៥ គ.ម** រួមមានការសាងសង់ផ្លូវក្រាលល្បាយក្រួសបានប្រវែង ២១៧គ.ម, សាងសង់ និងកែលម្អផ្លូវក្រាលកៅស៊ូពីរជាន់បានប្រវែង ១០១គ.ម, សាងសង់ផ្លូវក្រាលបេតុង បានប្រវែង ៧៧ គ.ម, សាងសង់ស្ពានបេតុង ចំនួន ១២កន្លែង ប្រវែងសរុប ៦៧៥ម និងសាងសង់សំណង់សិល្បការគ្រប់ប្រភេទចំនួន ២៦០៥កន្លែង និងក្រោមហិរញ្ញប្បទានសហប្រតិបត្តិការពីដៃគូអភិវឌ្ឍន៍បានស្ថាបនា និងកែលម្អផ្លូវក្រាលកៅស៊ូពីរជាន់ ប្រវែង ៩៣៥គ.ម។ ដើម្បីពង្រឹងគុណភាពសាងសង់ ក្រសួងបានចុះត្រួតពិនិត្យបច្ចេកទេសសាងសង់ និងថែទាំផ្លូវជនបទចំនួន ១៣០គម្រោង។ ទន្ទឹមនឹងនេះ មន្ទីរពិសោធន៍បានទទួលសំណាក ចំនួន ៧៧៣សំណាក និងបានពិសោធន៍រួចរាល់ ១០០ ចំនួន%៧៦២ សំណាក ។

គិតត្រឹមឆ្នាំ២០២៤នេះ ក្រសួងបានអនុវត្ត និងធ្វើបច្ចុប្បន្នភាពទិន្នន័យផ្លូវជនបទ សម្រេចបានផ្លូវក្រាលកៅស៊ូប្រវែង ៦ ៧២៣គ.ម និងបេតុង ប្រវែង ១ ៨០៤គ.ម ផ្លូវល្បាយក្រួសប្រវែង ៣១ ៧០៤គ.ម និងផ្លូវដីសប្រវែង ១០ ០២៩គ.ម **សរុបរួមប្រវែង ៥០ ២៦២គ.ម** និងមានសំណង់សិល្បការគ្រប់ប្រភេទ សរុបចំនួន ៤៨ ៨២២កន្លែង សរុបប្រវែង ៣១ ៥៥៧ម (ស្ពានបេតុង ចំនួន ២ ៣០៣កន្លែង សរុបប្រវែង ២៧ ៧៣៦ម ស្ពានដែក ចំនួន ៨៣កន្លែង សរុបប្រវែង ២ ១៤៦ម ស្ពានឈើ ចំនួន ១២៦កន្លែង សរុបប្រវែង ១ ៦៧៥ម លូមូល សរុបចំនួន ៣៦ ១២៨កន្លែង លូប្រអប់ ចំនួន ៤ ០៦៣កន្លែង) ក្នុងក្របខណ្ឌទូទាំងប្រទេស ដែលកំពុងស្ថិតនៅក្នុងបញ្ជីសារពើភ័ណ្ឌ និងប្រព័ន្ធគ្រប់គ្រងផ្លូវជនបទរបស់ក្រសួងអភិវឌ្ឍន៍ជនបទ។

### ២.២. កែលម្អលក្ខខណ្ឌនៃការរស់នៅរបស់សហគមន៍ជនបទ

សុខភាព អនាម័យ និងបរិស្ថានរស់នៅស្អាតជាកត្តានាំឱ្យការរស់នៅរបស់សហគមន៍ជនបទកាន់តែល្អប្រសើរឡើងជាលំដាប់ ធានាបានគុណភាពនៃជីវិតកាន់តែប្រសើរ និងអាយុសង្ឃឹមរស់ជាមធ្យម

(Life Expectancy) កាន់តែខ្ពស់។ ការផ្តល់ជូនសេវាផ្គត់ផ្គង់ទឹក ការសម្អាត និងអនាម័យ រួមទាំងបរិស្ថានស្អាត និងមានផាសុកភាពជូនប្រជាជនជនបទ គឺជាគោលបំណងនៃគោលនយោបាយទី២ របស់ក្រសួងអភិវឌ្ឍន៍ជនបទ ដែលបាននិងកំពុងចូលរួមចំណែកគាំទ្រដល់គោលនយោបាយរបស់រាជរដ្ឋាភិបាលក៏ដូចជាគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពនៅប្រទេសកម្ពុជា ។ លើសពីនេះ ប្រជាជនរស់នៅជនបទគ្រប់លំដាប់ថ្នាក់នៅតែបន្តទទួលបានការអប់រំផ្សព្វផ្សាយឱ្យយល់ដឹងអំពីការផ្លាស់ប្តូរទម្លាប់ និងការកែលម្អលក្ខខណ្ឌនៃការរស់នៅប្រកបដោយសុវត្ថិភាព តាមរយៈការអនុវត្តអនាម័យផ្ទាល់ខ្លួនតាមក្បួនខ្នាតត្រឹមត្រូវដើម្បីជៀសវាងការឆ្លងនូវជំងឺផ្សេងៗ ពិសេសគឺការបញ្ឈប់ជាស្ថាពរការបន្ទោបង់ពាសវាលពាសកាល។ ទន្ទឹមនឹងនេះដែរ ក្រសួងអភិវឌ្ឍន៍ជនបទបានចូលរួមអនុវត្តការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការដោយបានបន្តធ្វើប្រតិភូកម្មមុខងារផ្សព្វផ្សាយអនាម័យ និងសាងសង់ ជួសជុលបង្គន់អនាម័យសាធារណៈ និងជួសជុល ថែទាំអណ្តូងទឹកទៅឱ្យរដ្ឋបាលក្រុង-ស្រុក ចំនួន ១៥ស្រុក នៃខេត្តចំនួន ០៤ មានខេត្តកំពង់ស្ពឺ កំពង់ឆ្នាំង ត្បូងឃ្មុំ និងកំពត ដើម្បីបន្តអនុវត្ត ។

នៅឆ្នាំ២០២៤នេះ ជាលទ្ធផលសម្រេចបានក្នុងកម្មវិធីទី២នេះ សម្រេចគោលដៅបាន ៩៧% នៃផែនការប្រចាំឆ្នាំក្នុងនោះ ÷ ការងារផ្គត់ផ្គង់ទឹកស្អាត បានសាងសង់អណ្តូងចំនួន ៩៤៥អណ្តូង ក្នុងនោះគាំទ្រដោយថវិកាជាតិមានចំនួន ៣៧១អណ្តូង និងអង្គការមិនមែនរដ្ឋាភិបាលចំនួន ៥៧៤អណ្តូង, ជួសជុលអណ្តូងចំនួន ៥៩អណ្តូង គាំទ្រដោយថវិកាជាតិ, សាងសង់ស្រះសហគមន៍ចំនួន ៧៣ស្រះ ដែលក្នុងនោះគាំទ្រដោយថវិកាជាតិមានចំនួន ៥ស្រះ ហិរញ្ញប្បទានដៃគូអភិវឌ្ឍន៍ចំនួន ៣៦ស្រះ និងអង្គការមិនមែនរដ្ឋាភិបាលចំនួន ៣២ស្រះ, សាងសង់អាងត្រងទឹកភ្លៀងចំនួន ៦០អាង ក្នុងនោះគាំទ្រថវិកាជាតិមានចំនួន ៥៥អាង និងអង្គការមិនមែនរដ្ឋាភិបាលចំនួន ៥អាង, សាងសង់ប្រព័ន្ធចែកចាយទឹកតាមបណ្តាញបំពង់ខ្នាតតូចសហគមន៍ចំនួន ២៧ប្រព័ន្ធ គាំទ្រដោយថវិកាជាតិមានចំនួន ៦ប្រព័ន្ធ និងអង្គការមិនមែនរដ្ឋាភិបាលចំនួន ២១ប្រព័ន្ធ, សាងសង់ស្ថានីយផលិតទឹកសហគមន៍ចំនួន ៨០ស្ថានីយ ក្នុងនោះគាំទ្រដោយថវិកាជាតិចំនួន ១ស្ថានីយ និងអង្គការមិនមែនរដ្ឋាភិបាលចំនួន ៧៩ស្ថានីយ, ផ្តល់ធុងចម្រោះទឹកស្អាតចំនួន ២៥ ៣៨៦ធុង គាំទ្រដោយអង្គការមិនមែនរដ្ឋាភិបាល, ចែកធុងស្តុកទឹកចំនួន ១១ ៨៤៤ធុង ហិរញ្ញប្បទានដៃគូអភិវឌ្ឍន៍ចំនួន ៣ធុង និងអង្គការមិនមែនរដ្ឋាភិបាលចំនួន ១១ ៨៤១ធុង, សាងសង់ប្រឡាយទឹកចំនួន ១០ខ្សែ ដែលក្នុងនោះគាំទ្រដោយថវិកាជាតិមានចំនួន ១ខ្សែ និងអង្គការមិនមែនរដ្ឋាភិបាលចំនួន ៩ខ្សែ, សាងសង់បង្គន់អនាម័យគ្រួសារចំនួន ១៩ ០៣៥បង្គន់ ក្នុងនោះគាំទ្រដោយថវិកាជាតិចំនួន ៣ ៥២៧បង្គន់ ហិរញ្ញប្បទានដៃគូអភិវឌ្ឍន៍ចំនួន ៩៨បង្គន់ និងអង្គការមិនមែនរដ្ឋាភិបាលចំនួន ១៥ ៤១០បង្គន់, សាងសង់បង្គន់អនាម័យសាធារណៈចំនួន ១៩៨បង្គន់ គាំទ្រដោយអង្គការមិនមែនរដ្ឋាភិបាល, ផ្គត់ផ្គង់សម្ភារបង្គន់អនាម័យចំនួន ៨០ ២២៧ឈុត គាំទ្រដោយអង្គការមិនមែនរដ្ឋាភិបាល, សាងសង់កន្លែងលាងសម្អាតដៃចំនួន ១០ ២២១កន្លែង ហិរញ្ញប្បទានដៃគូអភិវឌ្ឍន៍ចំនួន ១២កន្លែង និងអង្គការមិនមែនរដ្ឋាភិបាលចំនួន ១០ ២០៩កន្លែង, សាងសង់ឡដុតសំរាមចំនួន ២១៤ឡ គាំទ្រដោយអង្គការមិនមែនរដ្ឋាភិបាល ចុះវិភាគអាសេនិចចំនួន ៦៤៤លើក គាំទ្រដោយអង្គការមិនមែនរដ្ឋាភិបាល និងបានស្រង់ទិន្នន័យហេដ្ឋារចនាសម្ព័ន្ធទឹកស្អាត និងអនាម័យចំនួន ៣៧៤លើក គាំទ្រដោយថវិកាជាតិ និងបានចុះអប់រំផ្សព្វផ្សាយពីទឹកស្អាត និងអនាម័យជូនប្រជាពលរដ្ឋចំនួន ១៣ ៥៩៤ នាក់

គាំទ្រដោយថវិកាជាតិ ។ គិតត្រឹមឆ្នាំ២០២៤នេះ លទ្ធផលសម្រេចបានលើសេវាផ្គត់ផ្គង់ទឹកស្អាតកម្រិតមូលដ្ឋាននៅតំបន់ជនបទប្រមាណ**៨៧%** និងការផ្គត់ផ្គង់ទឹកប្រកបដោយសុវត្ថិភាពនៅតំបន់ជនបទប្រមាណ **២១%** និងការផ្តល់សេវាអនាម័យជនបទកម្រិតមូលដ្ឋានប្រមាណ**៩២%** និងការគ្រប់គ្រងអនាម័យជនបទប្រកបដោយសុវត្ថិភាពប្រមាណ **៥១%**។ ក្រសួងអភិវឌ្ឍន៍ជនបទបានប្តេជ្ញាអនុវត្តផែនការសកម្មភាពជាតិស្តីពីការផ្គត់ផ្គង់ទឹកឱ្យសម្រេចបានគោលដៅអត្រាគ្របដណ្តប់ចំនួន **១០០% ត្រឹមឆ្នាំ ២០៣០** លើការទទួលបានសេវាទឹកស្អាត និងអនាម័យជនបទ។

ចំពោះការលើកកម្ពស់ការរស់នៅស្អាត និងអនាម័យ ក្រសួងបានបង្កើតយន្តការថ្នាក់ជាតិសហការជាមួយថ្នាក់ក្រោមជាតិ អនុវត្តកម្មវិធី «**បញ្ចប់ការបន្ទោបង់ពាសវាលពាសកាល**» (Open Defecation Free - ODF) ដោយគិតត្រឹមឆ្នាំ២០២៤នេះ ប្រជាជនជនបទ ទទួលបានសេវាអនាម័យកម្រិតមូលដ្ឋានប្រមាណ ៩២% ក្នុងនោះស្ថានភាពបញ្ចប់ការបន្ទោបង់ពាសវាលពាសកាល (ODF) មានភូមិចំនួន ១១ ៨៨១ ឃុំចំនួន១ ២៥៥ ស្រុកចំនួន១៣៤ បានបញ្ចប់ការបន្ទោបង់ពាសវាលពាសកាល(ODF) និងរាជធានី-ខេត្តបញ្ចប់ការបន្ទោបង់ពាសវាលពាសកាល (ODF) ចំនួន ១៤ រួមមានខេត្តស្វាយរៀង ព្រៃវែង កណ្តាល កំពង់ស្ពឺ កំពង់ឆ្នាំង កែប ព្រះសីហនុ កំពង់ចាម រតនគិរី សៀមរាប ត្បូងឃ្មុំ តាកែវ ស្ទឹងត្រែង និងរាជធានីភ្នំពេញ ដែលបានបញ្ចប់ការបន្ទោបង់កម្រិតខ្ពស់ ODF Plus។ បើធៀបនឹងផែនការឆ្នាំ២០២៣ គឺមានការកើនឡើងលើសការរំពឹងទុក ហើយបានគ្របដណ្តប់នៅតាមរាជធានី-ខេត្ត ដោយមានការចូលរួមសហការគ្នាយ៉ាងល្អពីសំណាក់អាជ្ញាធរគ្រប់លំដាប់ថ្នាក់ អង្គការមិនមែនរដ្ឋាភិបាលជាតិ-អន្តរជាតិ និងប្រជាពលរដ្ឋក្នុងមូលដ្ឋានប្រកបដោយការទទួលខុសត្រូវខ្ពស់។

ដោយឡែកគិតត្រឹមឆ្នាំ២០២៤ ក្រសួងបានរួមចំណែកក្នុងការកែលម្អលក្ខខណ្ឌនៃការរស់នៅរបស់សហគមន៍ជនបទ តាមរយៈសកម្មភាពផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ សម្រេចបានរួមមាន÷

**១- ការងារផ្គត់ផ្គង់ទឹកស្អាត** បានសាងសង់អណ្តូង ចំនួន ៦៣៨ ១៨២អណ្តូង, សាងសង់ស្រះសហគមន៍ ចំនួន ១០ ៦១៩ស្រះ, សាងសង់អាងត្រងទឹកភ្លៀង ចំនួន ៥៨ ៦១៤ អាង, សាងសង់ប្រព័ន្ធចែកចាយទឹកតាមបណ្តាញបំពង់ខ្នាតតូចសហគមន៍ ចំនួន ៤ ៧២៩ប្រព័ន្ធ, សាងសង់ពាងយក្សចំនួន ២៦៩ ៣៨៤ ពាង, ផ្តល់ធុងចម្រោះទឹកស្អាត ចំនួន ២៦ ០៤៦ធុង, សាងសង់ស្ថានីយផលិតទឹក ចំនួន២២០ស្ថានីយ, សាងសង់ប្រព័ន្ធស្រោចស្រពខ្នាតតូច និងថាមពលខ្នាតតូច ចំនួន ១៦ខ្សែ និងសាងសង់ប្រឡាយទឹកចំនួន ១០ខ្សែ, បណ្តុះបណ្តាលបច្ចេកទេសថែទាំ និងជួសជុលអណ្តូង ចំនួន ៤២វគ្គ អ្នកចូលរួមចំនួន១ ៨១១នាក់, អប់រំប្រជាពលរដ្ឋឱ្យយល់ដឹងពីការប្រើប្រាស់ទឹកស្អាត ចំនួន ៧៣វគ្គ អ្នកចូលរួមចំនួន ១៣ ៧០៦នាក់ ។

**២- ការងារលើកកម្ពស់អនាម័យជនបទ** បានសាងសង់បង្គន់គ្រួសារចំនួន ២ ៦០២ ១៩៥បង្គន់, សាងសង់បង្គន់អនាម័យសាធារណៈ ចំនួន ១០ ៥២០បង្គន់ និងសាងសង់បង្គន់អនាម័យនៅតំបន់លិចទឹកចំនួន ៩១០បង្គន់ ។ បើកវគ្គបណ្តុះបណ្តាល និងផ្សព្វផ្សាយគោលការណ៍ណែនាំដល់មន្ត្រីថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ចំនួន ៣៥៥វគ្គ អ្នកចូលរួម ចំនួន ១៣ ៩៣០នាក់, បានចុះអប់រំផ្សព្វផ្សាយជំរុញប្រជាពលរដ្ឋឱ្យប្រតិបត្តិអនាម័យល្អទាំង៣ គឺសាងសង់ និងប្រើប្រាស់បង្គន់អនាម័យ, ការលាងសម្អាតដៃនឹងសាប៊ូក្រោយពេលបន្ទោបង់ និងមុនពេលបរិភោគអាហារ និងការផឹកទឹកមានសុវត្ថិភាព អ្នកចូលរួម ៥៨ ៤០១នាក់, ក្រុមការងារវិមជ្ឈការ

និងវិសហាមជ្ឈការបន្តសម្របសម្រួលអនុវត្តការងារផ្គត់ផ្គង់ទឹកស្អាតសម្រេចបានចំនួន ៤៥ស្រុក និងការងារលើកកម្ពស់អនាម័យសម្រេចបានចំនួន ៤៦ស្រុក ដើម្បីអនុវត្តដោយរដ្ឋបាលស្រុកគោលដៅ។

ជារៀងរាល់ឆ្នាំ រាជរដ្ឋាភិបាល បានកំណត់យកថ្ងៃទី១៣ ខែវិច្ឆិកា ជាថ្ងៃប្រារព្ធទិវាជាតិលើកកម្ពស់អនាម័យជនបទ ដើម្បីជាសារក្រើនរំលឹកដាស់តឿនដល់បងប្អូនប្រជាពលរដ្ឋ និងគ្រប់ភាគីពាក់ព័ន្ធទាំងអស់ឱ្យយល់ដឹងអំពីសារៈសំខាន់ និងចូលរួមធ្វើឱ្យប្រសើរឡើងនូវស្ថានភាពអនាម័យនៅជនបទ ដើម្បីឈានទៅសម្រេចតាមគោលដៅកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល នីតិកាលទី៧ នៃរដ្ឋសភា សម្រាប់ការកសាង និងការការពារមាតុភូមិ ឆ្នាំ២០២៣-២០២៨ ដើម្បីបន្តជំរុញការអនុវត្តផែនការសកម្មភាពជាតិស្តីពីការផ្គត់ផ្គង់ទឹក ការសម្អាត និងអនាម័យជនបទ ជំហានទី២ ឱ្យសម្រេចអត្រាគ្របដណ្តប់៩០% នៅឆ្នាំ២០២៤ និងគោលដៅអភិវឌ្ឍន៍ដោយចីរភាពកម្ពុជា ១០០% នៅឆ្នាំ២០៣០ សំដៅឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ បញ្ហាប្រឈមក្នុងតំបន់ និងវិសមភាពនៃការទទួលបានសេវា។

### ២. ៣. ពិពិធកម្មសកម្មភាពសេដ្ឋកិច្ចជនបទ

ការងារពិពិធកម្មសកម្មភាពសេដ្ឋកិច្ចជនបទ សម្រេចបាននូវវឌ្ឍនភាពគួរឱ្យកត់សម្គាល់ ដោយក្រសួងបានផ្តួចផ្តើមគំនិតឱ្យបង្កើតការងារ មុខរបរ សហគ្រិនភាព ក៏ដូចជាសកម្មភាពសេដ្ឋកិច្ចនានា ក្រោមរូបភាពចម្រុះដោយមានទាំងមុខរបរកសិកម្ម និងមុខរបរមិនមែនកសិកម្មនៅតាមសហគមន៍ ដែលបាននិងកំពុងចូលរួមចំណែកលើកកម្ពស់ជីវភាពរស់នៅ ក៏ដូចជាកាត់បន្ថយភាពក្រីក្ររបស់ប្រជាជននៅតំបន់ជនបទ។ ការធ្វើពិពិធកម្មសេដ្ឋកិច្ចជនបទ បានផ្តល់ឱ្យគ្រួសារនីមួយៗទទួលបានប្រាក់ចំណូលបន្ថែម និងបានប្រែក្លាយសង្គមជនបទមានភាពសុខដុមរមនា កាត់បន្ថយការធ្វើចំណាកស្រុកទៅកាន់ទីក្រុង ឬឆ្លងដែនដោយប្រថុយប្រថានទៅប្រទេសជទៃ និងជំរុញឱ្យមានការផ្លាស់ប្តូរជីវភាពរស់នៅដោយផ្ទាល់របស់ប្រជាជននៅតំបន់ជនបទប្រកបដោយបរិយាបន្ន ទាំងផ្នែកសេដ្ឋកិច្ច សង្គមកិច្ច វប្បធម៌ និងបរិស្ថាន និងឈានទៅប្រែក្លាយរបៀបរបបនៃការរស់នៅឱ្យមានលក្ខណៈកាន់តែស៊ីវិល័យប្រហាក់ប្រហែលនឹងទីក្រុងផងដែរ។

សហគមន៍ជនជាតិដើមភាគតិច ក៏ទទួលបាននូវការយកចិត្តទុកដាក់ក្នុងការអភិវឌ្ឍទាំងផ្នែកសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ដោយពួកគាត់មានសិទ្ធិពេញលេញក្នុងការចូលរួមធ្វើសេចក្តីសម្រេចចិត្តនានាក្នុងការកសាងគោលនយោបាយជាតិ និងវិធានការសង្គម ដើម្បីឱ្យពួកគាត់អាចបំពេញនូវសេចក្តីត្រូវការចាំបាច់សម្រាប់ការរស់នៅប្រកបដោយសេចក្តីថ្លៃថ្នូរ គោរពអត្តសញ្ញាណ វប្បធម៌ ទំនៀមទម្លាប់ ភាសា និងប្រពៃណី។

នៅឆ្នាំ២០២៤នេះ បានចេញលិខិតទទួលស្គាល់អត្តសញ្ញាណសហគមន៍ជនជាតិដើមភាគតិច ចំនួន ២៣សហគមន៍ គាំទ្រដោយថវិកាជាតិ រៀបចំកិច្ចប្រជុំពេញអង្គបទបញ្ញាផ្ទៃក្នុង ចំនួន ២សហគមន៍ គាំទ្រដោយថវិកាជាតិ, រៀបចំវេទិកាជនជាតិដើមភាគតិច ចំនួន ១លើក គាំទ្រដោយថវិកាជាតិ និងពង្រឹងតួនាទីរចនាសម្ព័ន្ធគណៈកម្មការសហគមន៍ជនជាតិដើមភាគតិច ចំនួន ២លើក គាំទ្រដោយថវិកាជាតិ, បានប្រកាសទទួលស្គាល់ និងប្រគល់វិញ្ញាបនបត្រ "ភូមិគំរូ" ជូនដល់ "ភូមិគំរូ" ជ័យលាភីបានចំនួន ៣០ភូមិ, បាននិងកំពុងអនុវត្តគម្រោងភូមិគំរូចំនួន ៣៤ភូមិ ក្នុងនោះ"ភូមិសន្តិភាព" ចំនួន ៣០ភូមិ និង"ភូមិគំរូចលនាភូមិថ្មី" ចំនួន ៤ភូមិ, សាងសង់ស្រះគ្រួសារ ចំនួន ៥០ស្រះ គាំទ្រដោយថវិកាជាតិ, ផ្តល់កូនឈើហូបផ្លែចម្រុះ ចំនួន ២ ៨០០ដើម គាំទ្រដោយថវិកាជាតិ, ផ្តល់ពូជបន្លែចម្រុះចំនួន ១៩ ៦០០កញ្ចប់ គាំទ្រដោយថវិកា

ជាតិ, ផ្តល់សម្ភារធ្វើរោងជីកំប៉ុស្ត ចំនួន ៣១៥គ្រួសារ គាំទ្រដោយថវិកាជាតិ, បណ្តុះបណ្តាល គ.អ.ភ ខេត្តគោលដៅ ១៣ខេត្ត បាន ចំនួន ៤០វគ្គ ស្មើនឹង ២៣៦ភូមិ មានអ្នកចូលរួម ៨០០នាក់ គាំទ្រដោយថវិកាជាតិ, បណ្តុះបណ្តាលស្តីពីស្ទូនដំណាំគ្រួសារ និងរបៀបធ្វើជីកំប៉ុស្ត ក្នុងខេត្តគោលដៅ ចំនួន២ បានចំនួន ៩វគ្គ ដែលមានអ្នកចូលរួម សរុប ១៧៤នាក់គាំទ្រដោយថវិកាជាតិ, បណ្តុះបណ្តាលដល់សហគមន៍ស្តីពីការត្រៀមបង្ការ និងកាត់បន្ថយគ្រោះភ័យក្នុងសហគមន៍ ក្នុងខេត្តគោលដៅចំនួន៣ បានចំនួន ៨វគ្គ មានសិក្ខាកាមសរុប ១៦០នាក់ គាំទ្រដោយថវិកាជាតិ, បណ្តុះបណ្តាលពាក់ព័ន្ធការងារអភិវឌ្ឍន៍សហគមន៍ជនបទគាំទ្រដោយថវិកាជាតិ ការដាំដំណាំ ចិញ្ចឹមសត្វ ខ្សែច្រវ៉ាក់ផលិតកម្ម សេវាកម្មជាដើម បានចំនួន ៥៩វគ្គ អ្នកចូលរួម ១៤៤០នាក់ គាំទ្រដោយថវិកាជាតិ។ ចុះធ្វើបច្ចុប្បន្នភាពគណៈកម្មាធិការអភិវឌ្ឍន៍ភូមិ (គ.អ.ភ)ចំនួន ១៨០លើក គាំទ្រដោយថវិកាជាតិដោយបានសាងសង់ផ្ទះសំណាញ់កសិកម្មចំនួន ៤ខ្នង គាំទ្រដោយហិរញ្ញប្បទានដៃគូអភិវឌ្ឍន៍, សាងសង់ផ្ទះជូនប្រជាពលរដ្ឋ ចំនួន ១៣០ខ្នង គាំទ្រដោយអង្គការមិនមែនរដ្ឋាភិបាល, សាងសង់សាលារៀន ចំនួន ៦៧បន្ទប់ ដែលក្នុងនោះគាំទ្រដោយហិរញ្ញប្បទានដៃគូ ចំនួន ១បន្ទប់ និងអង្គការមិនមែនរដ្ឋាភិបាល ចំនួន ៦៦បន្ទប់, ជួសជុលសាលារៀនចំនួន ២១ខ្នង គាំទ្រដោយអង្គការមិនមែនរដ្ឋាភិបាល ផ្តល់ផ្ទាំងសូឡាជូនប្រជាពលរដ្ឋចំនួន ៥៩៣ផ្ទាំង គាំទ្រដោយអង្គការមិនមែនរដ្ឋាភិបាល, ផ្តល់រ៉ឺម៉កចំនួន ៣៣គ្រឿង ដែលក្នុងនោះ ដែលក្នុងនោះគាំទ្រដោយហិរញ្ញប្បទានដៃគូអភិវឌ្ឍន៍ ចំនួន ៤គ្រឿង និងអង្គការមិនមែនរដ្ឋាភិបាល ចំនួន ២៩គ្រឿង, សាងសង់កន្លែងប្រមូលផ្តុំកសិផល ចំនួន ២កន្លែង គាំទ្រដោយហិរញ្ញប្បទានដៃគូអភិវឌ្ឍន៍, សាងសង់កំពង់ជ ចំនួន ១កន្លែង គាំទ្រដោយហិរញ្ញប្បទានដៃគូអភិវឌ្ឍន៍ បណ្តុះបណ្តាលបំណិនជីវិត និងជំនាញមូលដ្ឋានជូនប្រជាពលរដ្ឋ ចំនួន ៣៥៩ ៤៩៨នាក់ ក្នុងនោះគាំទ្រដោយថវិកាជាតិមាន ចំនួន ៥ ៧១៥នាក់ ហិរញ្ញប្បទានដៃគូអភិវឌ្ឍន៍ចំនួន ៨៤០នាក់ និងអង្គការមិនមែនរដ្ឋាភិបាល ចំនួន ៣៥២ ៩៣៣នាក់។ ចុះតាមដានសិក្ខាកាមក្រោយវគ្គបណ្តុះបណ្តាល ចំនួន ១៨លើក គាំទ្រដោយថវិកាជាតិ។ ចងក្រងសហគមន៍សន្សំប្រាក់ចំនួន ៧០សហគមន៍ ដែលក្នុងនោះគាំទ្រដោយ ថវិកាជាតិចំនួន ២សហគមន៍ និងអង្គការមិនមែនរដ្ឋាភិបាលចំនួន ៦៨ សហគមន៍។ រៀបចំសិក្ខាសាលាផ្តល់នូវចំណេះដឹងពីគំនិតផ្តួចផ្តើមបង្កើតអាជីវកម្ម ៥វគ្គ មានសិក្ខាកាមចូលរួម១៤៧នាក់ គាំទ្រដោយថវិកាជាតិ។ ចងក្រងសហគមន៍/ក្រុមកសិករ ចំនួន ៤ ៣៤៥ក្រុម ដែលក្នុងនោះគាំទ្រដោយហិរញ្ញប្បទានដៃគូអភិវឌ្ឍន៍ចំនួន ១៨ក្រុម និងអង្គការមិនមែនរដ្ឋាភិបាល ចំនួន ៤ ៣២៧ក្រុម, សិក្ខាសាលាផ្សព្វផ្សាយស្តីពីការបង្កើនកម្រិតជីវភាព ប្រជាជនតំបន់ជនបទ ១៦វគ្គ មានសិក្ខាកាមចូលរួម ៧២៤នាក់ និងតាំងពិព័រណ៍ផលិតផលសហគមន៍ជនបទ ១លើក គាំទ្រដោយថវិកាជាតិ ។ បណ្តុះបណ្តាលមន្ត្រីរាជការ ចំនួន១ ៣១២នាក់ ក្នុងនោះគាំទ្រដោយថវិកាជាតិ ចំនួន ១ ២៧៨នាក់ និងហិរញ្ញប្បទានដៃគូអភិវឌ្ឍន៍ ចំនួន ៣៤នាក់, បណ្តុះបណ្តាលជំនាញមូលដ្ឋានសម្រាប់បង្កើតមុខរបររកប្រាក់ចំណូលបន្ថែមចំនួន១៩៩វគ្គ មានអ្នកចូលរួម ៤ ១២៦នាក់គាំទ្រដោយថវិកាជាតិ, បណ្តុះបណ្តាលជំនាញមូលដ្ឋានចល័តចំនួន ៤លើក គាំទ្រដោយថវិកាជាតិ។

ក្រសួងអភិវឌ្ឍន៍ជនបទ បាននិងកំពុងបន្តចូលរួមជំរុញកំណើនសេដ្ឋកិច្ចនៅជនបទ និងកាត់បន្ថយគម្លាតរវាងទីប្រជុំជន និងជនបទ។ ក្នុងឆ្នាំ២០២៤ នេះ ក្រសួងអនុវត្តសកម្មភាពការងារសម្រេចគោលដៅបានចំនួន ៩៨% នៃផែនការប្រចាំឆ្នាំ ដែលក្នុងនោះ ១- ការជំរុញការបង្កើតការងារ និងមុខ

របរនៅជនបទ ទទួលបាន ៩៤% នៃផែនការ, ២- ការជំរុញសកម្មភាពសេដ្ឋកិច្ចគ្រួសារនៅជនបទ ទទួលបាន ១០១% នៃផែនការ, ៣- ការបណ្តុះបណ្តាលធនធានមនុស្ស និងជំនាញមូលដ្ឋាន ទទួលបាន ៩៥% នៃផែនការ ៤- ការអភិវឌ្ឍចម្រុះសម្រាប់សហគមន៍ជនបទទទួលបាន ១០០% នៃផែនការ ៥- ការអភិវឌ្ឍ និងអភិរក្សជនជាតិដើមភាគតិច ទទួលបាន ១០១% នៃផែនការ និង ៦- ការលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាជនជនបទ ដោយមន្ទីរជំនាញទាំង២៥ ទទួលបាន ៩៩% នៃផែនការប្រចាំឆ្នាំ។

ដោយឡែក គិតត្រឹមឆ្នាំ២០២៤ ក្រសួងបានសម្រេចការងារធ្វើពិពិធកម្មសកម្មភាពសេដ្ឋកិច្ច ដែលគ្របដណ្តប់លើវិស័យសំខាន់ៗរួមមាន÷ **១-ការងារអភិរក្ស និងអភិវឌ្ឍន៍ជនជាតិដើមភាគតិច** បានចេញលិខិតទទួលស្គាល់អត្តសញ្ញាណសហគមន៍ជនជាតិដើមភាគតិចចំនួន ២០៣សហគមន៍, បានរៀបចំកិច្ចប្រជុំពេញអង្គបទបញ្ជាផ្ទៃក្នុងចំនួន ១០១សហគមន៍, រៀបចំទិវាជាតិជនជាតិដើមភាគតិចចំនួន ២០លើក, រៀបចំសិក្ខាសាលាផ្សព្វផ្សាយគោលនយោបាយជាតិស្តីពីការអភិវឌ្ឍជនជាតិដើមភាគតិចចំនួន ៣៦លើក, ពង្រឹងតួនាទី និងរចនាសម្ព័ន្ធគណៈកម្មការសហគមន៍ជនជាតិដើមភាគតិចចំនួន២៨លើក, **២- ការងារអភិវឌ្ឍន៍សហគមន៍** បានប្រកាសទទួលស្គាល់ និងប្រគល់វិញ្ញាបនបត្រ "ភូមិគំរូ" ជូនដល់ "ភូមិគំរូ" ជ័យលាភីបានចំនួន ៣០ភូមិ, បាននិងកំពុងអនុវត្តគម្រោងភូមិគំរូចំនួន ៣៤ភូមិ ក្នុងនោះ "ភូមិសន្តិភាព" ចំនួន ៣០ភូមិ និង "ភូមិគំរូចលនាភូមិថ្មី" ចំនួន ៤ភូមិ។ ផ្សព្វផ្សាយសារាចរណែនាំស្តីពីការបង្កើត និងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការអភិវឌ្ឍន៍ភូមិ គ្របខណ្ឌទូទាំង (ភ.អ.គ) ២៦០០ក្ប ៤ ៣៤៧នាក់ និងចែកសៀវភៅសារាចរណែនាំ ចំនួន ប្រទេស អ្នកចូលរួមចំនួន◌ាល។ បណ្តុះបណ្តាលគ ៨ ៦៩៧ភូមិ ភ ចំនួន.អ.ប្រមាណ ៥៨.១% នៃភូមិសរុបបច្ចុប្បន្ន, រៀបចំសិក្ខាសាលាផ្លាស់ប្តូរបទពិសោធន៍ការងារពង្រឹងសមត្ថភាព គ១ ២៣០នាក់ ១១ខេត្ត អ្នកចូលរួមចំនួន ភ បានចំនួន.អ. , រៀបចំសិក្ខាសាលាចែករំលែកបទពិសោធន៍ ស្តីពីគោលគំនិតនៃការអភិវឌ្ឍសហគមន៍ ចំនួន ១លើក អ្នកចូលរួមចំនួន ៩០នាក់។ ការអភិវឌ្ឍភូមិចម្រុះចំនួន ១០១ភូមិ ក្នុងនោះបានផ្តល់ស្រះគ្រួសារចំនួន ៥២៣ស្រះ និងផ្តល់កូនត្រីសម្រាប់ចិញ្ចឹម ៧៤ ៨៧០ក្បាល ផ្តល់កូនឈើហូបផ្លែចម្រុះ ៦០ ៦៤៥ដើម កូនឈើចម្រុះ ២ ១០០ដើម និងពូជបន្លែចម្រុះចំនួន ៣ ៧៣៧គ្រួសារ ផ្តល់មេគោចំនួន ៣១ក្បាល មេជ្រូកចំនួន២៩០ក្បាល ពូជមាន់ ចំនួន ៦ ១៩៥ក្បាល ពូជស្រូវ ២ ៨២៥គីឡូក្រាម និងពូជពោតក្រហម ចំនួន ២០០គីឡូក្រាម។ បណ្តុះបណ្តាលសន្តិសុខស្បៀងជាលក្ខណៈគ្រួសារសម្រាប់គ្រូបង្គោលមន្ត្រីថ្នាក់ខេត្តស្រុក ចំនួន ២០នាក់ បណ្តុះបណ្តាលសួនដំណាំគ្រួសារ និងរៀបធ្វើជីកំប៉ុស្តដល់គ្រួសារសហគមន៍ ១០៧វគ្គ អ្នកចូលរួមចំនួន ២ ៤២៩នាក់, ផ្តល់សម្ភាររោងជីកំប៉ុស្ត និងបន្លែចម្រុះចំនួន ៤ ៥៧០គ្រួសារ, បណ្តុះបណ្តាលការអប់រំក្រៅប្រព័ន្ធស្តីពីអក្ខរៈកម្ម ចំនួន ២ ៥៦៧នាក់, បណ្តុះបណ្តាលគ្រូបង្គោលស្តីពីការត្រៀមបង្ការ និងកាត់បន្ថយហានិភ័យចំនួន ៩១វគ្គ អ្នកចូលរួម ២ ៩០០នាក់, បណ្តុះបណ្តាលភាពជាអ្នកដឹកនាំកម្រិតភូមិ និងផ្នែកកសិកម្មផ្តោតលើការចិញ្ចឹមសត្វ ដាំបន្លែ កែច្នៃម្ហូបអាហារ និងចលនាភូមិថ្មី ចំនួន ១០៧វគ្គ សិក្ខាកាមសរុប ៣ ១៣៥នាក់ និងបណ្តុះបណ្តាលជំនាញជួសជុលម៉ូតូ ជួសជុលគ្រឿងយន្តកសិកម្ម អ៊ុតសក់ ផាត់មុខ កុំព្យូទ័រ រដ្ឋបាល ភាសាអង់គ្លេស បច្ចេកទេសដាំដំណាំ ធ្វើជីកំប៉ុស្ត បច្ចេកទេសចិញ្ចឹមត្រី-មាន់-ជ្រូក បច្ចេកទេសបណ្តុះកូនឈើ បច្ចេកទេសជួសជុលអណ្តូងស្នប់ចំនួន ៤៧៥វគ្គ អ្នកចូលរួម ១១ ៦៧៣នាក់ និងអភិវឌ្ឍន៍ភូមិគំរូ បានចំនួន ៣០ភូមិ, **៣- ការងារជំរុញសកម្មភាពសេដ្ឋកិច្ចគ្រួសារ÷**

តាមរយៈឥណទានជនបទ ក្រសួងមានទ្រព្យសកម្មសរុបចំនួន ២ ៣២៦ ១៦៦ ៦៤០,៦៥ រៀល(ពីរប៊ីលាន បីរយម្ភៃប្រាំមួយលាន មួយរយហុកសិបប្រាំមួយពាន់ ប្រាំមួយរយសែសិបរៀល និងហុកសិបប្រាំសេន) មានអ្នកខ្ចីសរុប ៤១៨នាក់ ស្រីចំនួន ២៨៧នាក់ នៅភូមិគោលដៅចំនួន ៧៦ភូមិ ៤១ឃុំ ២១ស្រុក ក្នុងខេត្តគោលដៅ ចំនួន ៩ និងសាងសង់ផ្សារសហគមន៍ជនបទ ចំនួន ៦ផ្សារ ។ រៀបចំតាំងពិព័រណ៍ផលិតផលជនបទ ក្រោមប្រធានបទ«**ភូមិខ្ញុំផលិតផលខ្ញុំ**» ចំនួន ៦លើក ផ្តល់មេគោចំនួន ១០០ក្បាល បណ្តុះបណ្តាល បច្ចេកទេសផលិតឡជីវឧស្ម័ន- ត្បាញក្រម៉ា- ត្បាញហូល- ចិញ្ចឹមត្រី- ចិញ្ចឹមមាន់ អ្នកចូលរួម ៦១៦នាក់ សិក្ខាសាលាផ្សព្វផ្សាយ អត្ថប្រយោជន៍ឡជីវឧស្ម័ន និងការគ្រប់គ្រងអាជីវកម្មខ្នាតតូច, ការប្រើប្រាស់ឥណទានជនបទ និងចងក្រងក្រុមសន្សំ អ្នកចូលរួម ១ ៨៥៣នាក់, បណ្តុះបណ្តាលស្តីពីការបង្កើតគំនិតអាជីវកម្ម (បច្ចេកទេសផលិតសាប៊ូលាងចាន)អ្នកចូលរួម ១ ៥៩៩នាក់ និងបង្កើតសិប្បកម្មផលិតសាប៊ូ ចំនួន ៦៣កន្លែង, សិក្ខាសាលាផ្តល់គំនិតផ្តួចផ្តើម និងបណ្តុះបណ្តាលភាពជាសហគ្រិនក្នុងដំណើរការប្រតិបត្តិការការគ្រប់គ្រងអាជីវកម្មខ្នាតតូច អ្នកចូលរួម ៥៥៦នាក់, បណ្តុះបណ្តាលគំនិតកែច្នៃផលិតផលសហគន៍ជនបទ អ្នកចូលរួម ៩០នាក់, បណ្តុះបណ្តាលគោលការណ៍សហគមន៍សន្សំប្រាក់ និងសិក្ខាសាលាផ្លាស់ប្តូរបទពិសោធន៍ជោគជ័យ និងបញ្ហាប្រឈម អ្នកចូលរួម ៥២៤នាក់, សិក្ខាសាលាស្តីពីការបូកសរុបលទ្ធផលប្រចាំឆ្នាំលើការងារឥណទានជនបទ ១៤វគ្គ (១វគ្គ/ឆ្នាំ) អ្នកចូលរួម ៦៩៤នាក់ សិក្ខាសាលាស្វែងយល់ពីទីផ្សាររបស់ផលិតផលជនបទ ផ្លាស់ប្តូរបទពិសោធន៍ជោគជ័យ និងបញ្ហាប្រឈមរបស់ទីផ្សារ និងចែករំលែកការយល់ដឹង និងផ្សព្វផ្សាយពីផលិតផលសម្រេច អ្នកចូលរួម ១ ០៤២នាក់, បណ្តុះបណ្តាលកិច្ចបញ្ជីការគ្រប់គ្រងហិរញ្ញវត្ថុក្នុងអាជីវកម្ម អ្នកចូលរួម ៤០នាក់ **៤- ការងារបណ្តុះបណ្តាលធនធានមនុស្ស និងជំនាញអាជីព** បានបណ្តុះបណ្តាលមន្ត្រីរាជការ មានអ្នកចូលរួម ៦៤ ១១៤នាក់ ក្នុងនោះបណ្តុះបណ្តាលក្នុងប្រទេស អ្នកចូលរួម ៦២ ៩៥០ នាក់ និងបណ្តុះបណ្តាលក្រៅប្រទេស អ្នកចូលរួម ១ ១១២នាក់, បណ្តុះបណ្តាលជំនាញមូលដ្ឋានសម្រាប់បង្កើតមុខរបររកប្រាក់ចំណូលបន្ថែម ចំនួន ២ ៤៥៤វគ្គ អ្នកចូលរួម ៤៤ ៧៦៩ នាក់ ក្នុងនោះវគ្គបណ្តុះបណ្តាល រយៈពេលខ្លីចំនួន ១ ៤៦៩វគ្គ អ្នកចូលរួម ២៧ ១៧៣នាក់, វគ្គបណ្តុះបណ្តាលរយៈពេលវែង ចំនួន ៩៨៥វគ្គ អ្នកចូលរួម ១៧ ៥៩៦នាក់, រៀបចំសិក្សាតម្រូវការបណ្តុះបណ្តាលលើការអភិវឌ្ឍធនធានមនុស្សរបស់មន្ត្រីរាជការក្រសួងអភិវឌ្ឍន៍ជនបទ ចំនួន ៤លើក, បោះពុម្ពផ្សព្វផ្សាយព្រឹត្តិបត្រព័ត៌មានរបស់ក្រសួង ចំនួន ២២លេខ និងបោះពុម្ពនិទ្ទានុលេខ៍ចំនួន១០ឆ្នាំ និងបោះពុម្ពប្រតិទិនចំនួន ១ឆ្នាំ និងរៀបចំឯកសារព័ត៌មាន ផលិតវីដេអូព័ត៌មានសម្រាប់ផ្សាយតាមស្ថានីយវិទ្យុ-ទូរទស្សន៍ចំនួន ១ ៤២១លើក។

### ២.៤. ពង្រឹងសេវាគាំទ្ររដ្ឋបាល និងកិច្ចការទូទៅ

ក្រសួងអភិវឌ្ឍន៍ជនបទ បានយកចិត្តទុកដាក់យ៉ាងខ្លាំង ក្នុងការពង្រឹងសេវាគាំទ្ររដ្ឋបាល និងកិច្ចការទូទៅដើម្បីធានាប្រសិទ្ធភាពនៃការគ្រប់គ្រង ក្រសួងគាំទ្រដល់កម្មវិធីអភិវឌ្ឍន៍ធនធានមនុស្សនិងអភិបាលកិច្ចល្អ ការអភិវឌ្ឍប្រកបដោយនិរន្តរភាពទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ សំដៅរួមចំណែកក្នុងការអនុវត្តកម្មវិធីកែទម្រង់រដ្ឋបាលសាធារណៈ, កែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ, កែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ និងកម្មវិធីកែទម្រង់ដទៃទៀត ឱ្យកាន់តែមានប្រសិទ្ធភាពខ្ពស់។ សមត្ថភាពរបស់ស្ថាប័ន រួមនឹងសមត្ថភាពរបស់មន្ត្រីរាជការ មានការរីកចម្រើនគួរឱ្យកត់សម្គាល់តាមរយៈ

ការបណ្តុះបណ្តាល និងការពង្រឹងសមត្ថភាព។ ការរៀបចំផែនការ ការគ្រប់គ្រងនិងការប្រើប្រាស់ថវិកាត្រូវបានរៀបចំប្រកបដោយគុណភាព និងកាន់តែប្រសើរឡើង ស្របតាមគោលការណ៍ណែនាំ ក៏ដូចជាបទដ្ឋានគតិយុត្តដែលបានដាក់ចេញដោយរាជរដ្ឋាភិបាល។

នៅឆ្នាំ២០២៤នេះ កម្មវិធីពង្រឹងសេវាគាំទ្ររដ្ឋបាល និងកិច្ចការទូទៅ អនុវត្តសកម្មភាពការងារទទួលបានលទ្ធផលប្រមាណ ៩៨% នៃផែនការឆ្នាំ។ ក្រសួងសម្រេចបានសមិទ្ធផលធំៗជាច្រើន និងបានរួមចំណែកយ៉ាងសំខាន់ក្នុងការអនុវត្តការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ពិសេសក្នុងដំណាក់កាលទី៤ គឺការកសាងគណនេយ្យភាពសមិទ្ធកម្ម/ស្ថាប័នីយកម្មប្រព័ន្ធថវិកាព័ត៌មានសមិទ្ធកម្ម។

ស្តែងចេញពីគោលនយោបាយខាងលើ ក្រសួងបានរៀបចំផែនការវិនិយោគសាធារណៈបីឆ្នាំរំកិល (PIP) ឆ្នាំ២០២៤-២០២៦, ២០២៥-២០២៧ និង២០២៦-២០២៨ ដើម្បីស្វែងរកហិរញ្ញប្បទានបន្ថែមទៀតពីដៃគូអភិវឌ្ឍន៍ និងប្រភពហិរញ្ញប្បទាននានា សំដៅបំពេញនូវតម្រូវការជាក់ស្តែងនៃការអភិវឌ្ឍន៍ជនបទនៅកម្ពុជា។

គម្រោងវិនិយោគសាធារណៈ ក្រោមជំនួយហិរញ្ញប្បទានពីដៃគូអភិវឌ្ឍន៍ទាំងទ្វេភាគី និងពហុភាគីបានជួយជំរុញការអភិវឌ្ឍនៅតំបន់ជនបទ ឱ្យមានសន្ទុះយ៉ាងលឿន ពិសេសបានរួមចំណែកអភិវឌ្ឍន៍លើផ្នែកហេដ្ឋារចនាសម្ព័ន្ធទាំងផ្នែករឹងនិងទន់ និងបានលើកកម្រិតជីវភាពរស់នៅរបស់ប្រជាជនជនបទបានល្អប្រសើរឡើងជាបន្តបន្ទាប់។ ជាមួយគ្នានេះ ក្រសួងបានយកចិត្តទុកដាក់រៀបចំផែនការយុទ្ធសាស្រ្តថវិកា (BSP) ឆ្នាំ២០២៤-២០២៦ ដោយបានធ្វើសមាហរណកម្មថវិកាមូលធន និងថវិកាចរន្តបញ្ចូលគ្នាតាមកម្មវិធី អនុកម្មវិធី ដែលអាចឆ្លើយតបបាននឹងកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

ក្រសួងបានរៀបចំនូវកិច្ចព្រមព្រៀងសមិទ្ធកម្មទាំងបីកម្រិត ធ្វើការផ្សព្វផ្សាយថវិកាពលរដ្ឋ និងបានរៀបចំនូវសៀវភៅគោលការណ៍ណែនាំស្តីពីការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ សំដៅផ្តល់ជាត្រីវិស័យក្នុងការអនុវត្តថវិកាកម្មវិធីប្រចាំឆ្នាំ ដើម្បីជួយសម្រួលដល់ដំណើរការអនុវត្តថវិកាឱ្យមានប្រសិទ្ធភាព និងស័ក្តិសិទ្ធភាព រក្សាបានតុល្យភាពនៃលំហូរសាច់ប្រាក់ និងធានានិរន្តរភាពការអនុវត្តផែនការសកម្មភាពពីដើមឆ្នាំដល់ចុងឆ្នាំ។ ការវិភាជកញ្ចប់ថវិកាប្រចាំឆ្នាំ ក្រសួងបានបង្កើតក្រុមការងារថវិកាដើម្បីផ្តល់ការណែនាំរៀបចំ និងបែងចែកកញ្ចប់ថវិកាទៅតាមកម្មវិធីអាទិភាពនីមួយៗរបស់ក្រសួងប្រកបដោយបរិយាបន្ន។ ឆ្នាំ២០២៤នេះ ការងារពង្រឹងគុណភាពប្រព័ន្ធគ្រប់គ្រងផែនការអភិវឌ្ឍន៍ជនបទអនុវត្តបាន ១០០% ធៀបនឹងផែនការឆ្នាំ ក្នុងនោះបានរៀបចំសិក្ខាសាលាស្តីពីការកំណត់ទិន្នន័យស្ថិតិការរៀបចំផែនការយុទ្ធសាស្រ្តថវិកា និងថវិកាកម្មវិធី ព្រមទាំងផែនការវិនិយោគសាធារណៈរយៈពេលមធ្យមចំនួន ៥វគ្គ អ្នកចូលរួមចំនួន ៦៨០ នាក់, ចុះពង្រឹងការរៀបចំផែនការយុទ្ធសាស្រ្តថវិកា និងប្រមូលទិន្នន័យស្ថិតិវិស័យអភិវឌ្ឍន៍ជនបទតាមមន្ទីរអភិវឌ្ឍន៍ជនបទរាជធានី-ខេត្ត ចំនួន ៩៧ លើក, រៀបចំសិក្ខាសាលាពិគ្រោះយោបល់ដើម្បីប្រមូលធាតុចូល និងធ្វើបច្ចុប្បន្នភាពសេចក្តីព្រាងគោលការណ៍ណែនាំការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ, បានរៀបចំសិក្ខាសាលាស្តីពីត្រួតពិនិត្យ វាយតម្លៃថវិកាសមិទ្ធកម្ម និងលទ្ធផលរបស់អង្គការក្រៅរដ្ឋាភិបាល ដែលចុះកិច្ចព្រមព្រៀងជាមួយនឹងក្រសួងចំនួន ៤វគ្គ អ្នកចូលរួម ២៤៩ នាក់, ចុះតាមដាន វាយតម្លៃថវិកាសមិទ្ធកម្ម និងត្រួតពិនិត្យការអនុវត្តកិច្ចព្រមព្រៀងជាមួយអង្គការដៃគូចំនួន ៣០ លើក និងបានរៀបចំបន្តកិច្ចព្រមព្រៀងសហប្រតិបត្តិការរវាងក្រសួងអភិវឌ្ឍន៍ជនបទ

និងអង្គការមិនមែនរដ្ឋាភិបាល ចំនួន ១១កិច្ចព្រមព្រៀង (អង្គការ Wateraid, IDE, SADP, RDI, WHI, AOC, GNC, Johanniter, TGF, CSI, Plan International)។ ការងារបង្កើនប្រសិទ្ធភាពនៃការប្រើប្រាស់ថវិកាកម្មវិធី អនុវត្តបាន ១០០% ក្នុងនោះបានធ្វើសិក្ខាសាលាពង្រឹងការប្រើប្រាស់ប្រព័ន្ធ FMIS និងផ្សព្វផ្សាយលទ្ធផលនៃការអនុវត្តថវិកាកម្មវិធី ព្រមទាំងប្រព័ន្ធ SARMIS ចំនួន ២ វគ្គ អ្នកចូលរួម ៣៦០ នាក់, រៀបចំ និងចុះផ្ទៀងផ្ទាត់បញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋបានចំនួន ២៥រាជធានី-ខេត្ត និងចុះត្រួតពិនិត្យប្រសិទ្ធភាពនៃការអនុវត្តថវិកាកម្មវិធី បានចំនួន ២៥ខេត្ត។ ការងារសវនកម្មផ្ទៃក្នុង និងអធិការកិច្ច អនុវត្តបាន ៩២% ធៀបនឹងផែនការឆ្នាំ ក្នុងនោះបានចុះធ្វើសវនកម្មនៅអង្គភាពចំនួន ២៩ អង្គភាព រួមមានមន្ទីរអភិវឌ្ឍន៍ជនបទខេត្តចំនួន ២២ នាយកដ្ឋានចំនួន៣ និងគម្រោងចំនួន ៤គម្រោង បានតាមដានអនុសាសន៍សវនកម្មនៅ ៥សវនដ្ឋាន រួមមាន មន្ទីរអភិវឌ្ឍន៍ជនបទខេត្តចំនួន ៥ (ខេត្តពោធិ៍សាត់ បន្ទាយមានជ័យ ឧត្តរមានជ័យ ប៉ៃលិន និងខេត្តរតនគីរី), បានរៀបចំសិក្ខាសាលាផ្សព្វផ្សាយសវនកម្មផ្ទៃក្នុងចំនួន ១លើក នៅមន្ទីរអភិវឌ្ឍន៍ជនបទ ខេត្តបាត់ដំបង ស្តីពី«**ប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុង និងការងារសវនកម្មផ្ទៃក្នុង**» មានមន្ត្រីចូលរួម ចំនួន ២៥ នាក់, បានចុះធ្វើអធិការកិច្ចនៅតាមមន្ទីរអភិវឌ្ឍន៍ជនបទរាជធានី-ខេត្ត ចំនួន២២លើក និងបានចុះផ្សព្វផ្សាយនីតិវិធីអធិការកិច្ចបានចំនួន៨ខេត្ត មានអ្នកចូលរួមសរុប ២០០នាក់ និងបានដោះស្រាយពាក្យបណ្តឹងបានចំនួន៤ករណី។ ការពង្រឹងប្រសិទ្ធភាពនៃការគ្រប់គ្រងរដ្ឋបាល, ការងារជនមានពិការភាព និងការងារយេនឌ័រ អនុវត្តសកម្មភាពបាន ៩៩% ក្នុងនោះបានរៀបចំសិក្ខាលាលាផ្សព្វផ្សាយស្តីពីទស្សនៈយេនឌ័រ និងអនុសញ្ញាស៊ី-ដ (CEDAW) និងលើកកម្ពស់សិទ្ធិជនមានពិការភាពចំនួន ៥វគ្គ អ្នកចូលរួមចំនួន ៣៥០ នាក់, ធ្វើការចុះត្រួតពិនិត្យ និងតាមដានការបញ្ជ្រាបយេនឌ័រ នៅតាមបណ្តារាជធានី-ខេត្ត និងសហគមន៍គោលដៅចំនួន ៨ លើក, ចុះត្រួតពិនិត្យ និងវាយតម្លៃការគ្រប់គ្រងរដ្ឋបាល និងបុគ្គលិក ចំនួន ២០លើក និងបានរៀបចំសិក្ខាសាលាផ្សព្វផ្សាយស្តីពីការងារគ្រប់គ្រងរដ្ឋបាលនិងបុគ្គលិកនៅមន្ទីរអភិវឌ្ឍន៍ជនបទ ចំនួន ០៩លើក រួមមាន ទីស្តីការក្រសួង ខេត្តកណ្តាល តាកែវ កំពង់ស្ពឺ បាត់ដំបង ព្រះវិហារ បន្ទាយមានជ័យ កំពង់ចាម និងខេត្តស្វាយរៀង សរុបសិក្ខាកាមចូលរួម ចំនួន ៥៦៦ នាក់ និងបានរៀបចំបង្កើតគណៈកម្មការ និងក្រុមការងារបច្ចេកទេស ចំនួន ៥១ សេចក្តីសម្រេច ដើម្បីជាយន្តការសម្រាប់ពង្រឹងស្ថាប័ន និងបានរៀបចំសិក្ខាសាលាស្តីពីការប្រើប្រាស់បច្ចេកទេសព័ត៌មានចំនួន ១វគ្គ អ្នកចូលរួម ៦៥នាក់ និងបំពាក់ម៉ាស៊ីនស្កេនវត្តមានចំនួន១ឈុត, បានរៀបចំផែនការអភិវឌ្ឍន៍ប្រព័ន្ធគ្រប់គ្រងលំហូរឯកសារ)E-signing) កម្មវិធីបណ្ណាល័យអេឡិចត្រូនិក) E-Library), បានចាត់បញ្ជូនមន្ត្រីរាជការនៃក្រសួងអភិវឌ្ឍន៍ជនបទសរុបចំនួន១៥០នាក់ចូលរួមវគ្គបណ្តុះបណ្តាលបច្ចេកវិទ្យាឌីជីថល នៅវិទ្យាស្ថានអភិបាលកិច្ចឌីជីថលនៃបណ្ឌិត្យសភាបច្ចេកវិទ្យាឌីជីថលកម្ពុជារបស់ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍,បាននិងកំពុងសហការជាមួយក្រុមការងារបច្ចេកទេសក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ រៀបចំហេដ្ឋារចនាសម្ព័ន្ធ និងតភ្ជាប់បណ្តាញអ៊ីនធឺណិតនៃទីស្តីការក្រសួងឡើងវិញ ។ ចំពោះសេវាគាំទ្រគោលនយោបាយអនុវត្តសកម្មភាពបាន ១០០% ក្នុងនោះសកម្មភាពសេវាគាំទ្ររដ្ឋបាល ហិរញ្ញវត្ថុ និងគោលនយោបាយរបស់ក្រសួងអភិវឌ្ឍន៍ជនបទ សម្រេចបាន ១០០% ការជួសជុលថែទាំអគាររដ្ឋបាល, ការផ្គត់ផ្គង់សម្ភារបរិក្ខារបច្ចេកទេសមិនមែនព័ត៌មានវិទ្យា និងការផ្គត់ផ្គង់សម្ភារបរិក្ខារបច្ចេកទេសព័ត៌មានវិទ្យាសម្រេចបាន ១០០%។

## ៣. បញ្ហាប្រឈម

ទន្ទឹមនឹងការសម្រេចបានសមិទ្ធផលជាច្រើន ក្រសួងក៏បាននិងកំពុងជួបប្រទះនូវបញ្ហា និងការប្រឈមមួយចំនួនក្នុងដំណើរការអភិវឌ្ឍដែលទាមទារឱ្យមានការដោះស្រាយជាប្រព័ន្ធ និងទាន់ពេលវេលាប្រកបដោយប្រសិទ្ធភាពនិងការទទួលខុសត្រូវខ្ពស់ ក្នុងការឆ្លើយតបទៅនឹងសេចក្តីត្រូវការជាក់ស្តែងរបស់ប្រជាជនជនបទសំដៅកាត់បន្ថយភាពក្រីក្រ ព្រមទាំងលើកកម្ពស់កម្រិតជីវភាពរស់នៅរបស់ប្រជាជនជនបទផងដែរ។ ជាមួយគ្នានេះ ក្រសួង បានកត់សម្គាល់ឃើញមានបញ្ហាមួយចំនួន បាននិងកំពុងកើតមានឡើងនៅតាមមូលដ្ឋានរាជធានី-ខេត្ត ដែលបង្កឱ្យមានការប្រឈមមួយចំនួនក្នុងដំណើរការអភិវឌ្ឍន៍ជនបទ ជាអាទិ៍÷

### ៣.១ បញ្ហា

**កម្មវិធីទី១÷ ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងគមនាគមន៍**

- បរិមាណផ្លូវក្រាលកៅស៊ូ និងបេតុងនៅតំបន់ជនបទ នៅមានអត្រាទាប
- ថវិកាសម្រាប់ការងារថែទាំផ្លូវជនបទនៅមានកម្រិត
- ការដឹកជញ្ជូនលើសទម្ងន់កម្រិតកំណត់នៅលើផ្លូវជនបទ បណ្តាលឱ្យខូចផ្លូវឆាប់រហ័ស
- ការចាក់ដីលើកកម្ពស់លំនៅឋានរបស់ប្រជាពលរដ្ឋខ្ពស់ជាងតួផ្លូវនាំឱ្យប៉ះពាល់ដល់ប្រព័ន្ធបង្ហូរទឹក និងបណ្តាលឱ្យឆាប់ខូចផ្លូវជនបទ
- កង្វះខាតវត្ថុធាតុដើមសម្រាប់ការងារសាងសង់ផ្លូវ
- ការប្រែប្រួលអាកាសធាតុ និងគ្រោះមហន្តរាយធម្មជាតិ។

**កម្មវិធីទី២÷ ការកែលម្អលក្ខខណ្ឌនៃការរស់នៅរបស់សហគមន៍ជនបទ**

- អត្រានៃគ្រួសារជនបទទទួលបានសេវាទឹកស្អាត និងអនាម័យដែលគ្រប់គ្រងដោយសុវត្ថិភាព (Safely Managed) នៅមានកម្រិត
- អត្រាគ្របដណ្តប់សេវាទឹកស្អាត និងអនាម័យជនបទ នៅតំបន់ដាច់ស្រយ៉ាល និងតំបន់ដែលមានបរិស្ថានប្រឈមនៅមានកម្រិត
- ការប្រែប្រួលអាកាសធាតុ និងគ្រោះមហន្តរាយធម្មជាតិ បានប៉ះពាល់ដល់ហេដ្ឋារចនាសម្ព័ន្ធទឹកស្អាត និងអនាម័យជនបទ។
- វិសមភាពនៃការទទួលបានសេវាទឹកស្អាត និងអនាម័យជនបទ ។

**កម្មវិធីទី៣÷ ការធ្វើពិពិធកម្មសកម្មភាពសេដ្ឋកិច្ចជនបទ**

- គណៈកម្មាធិការអភិវឌ្ឍន៍ភូមិ (គ.អ.ភ) មិនទាន់ដំណើការល្អនៅឡើយ
- កង្វះឧបករណ៍បច្ចេកទេស និងសម្ភារឧបទ្ទេសសិក្សា នៅតាមមជ្ឈមណ្ឌលបណ្តុះបណ្តាលជំនាញមូលដ្ឋាន
- ធនធានថវិកាក្នុងការអនុវត្តនីតិវិធីនានាឈានទទួលស្គាល់អត្តសញ្ញាណជនជាតិដើមភាគតិចនៅមានកម្រិត
- ខ្វះមន្ត្រីជំនាញឥណទាន ដើម្បីគ្រប់គ្រងឥណទានតាមបណ្តាខេត្តគោលដៅ
- ធនធានថវិកាក្នុងការអនុវត្តនីតិវិធីនានាឈានទៅទទួលស្គាល់អត្តសញ្ញាណជនជាតិដើមភាគតិចនៅមានកម្រិត។

**កម្មវិធីទី៤÷ ការពង្រឹងសេវាគាំទ្ររដ្ឋបាល និងកិច្ចការទូទៅ**

- កង្វះខាតធនធាតថវិកា និងធនធានមនុស្ស ដើម្បីឆ្លើយតបនឹងតម្រូវការអភិវឌ្ឍន៍ជនបទ
- កង្វះខាតឯកសារគតិយុត្តដើម្បីអនុវត្តការងារឱ្យមានប្រសិទ្ធភាពខ្ពស់
- សម្ភារ និងគ្រឿងបរិក្ខារបច្ចេកទេសសម្រួលដល់ការបំពេញការងារប្រចាំថ្ងៃមិនទាន់មានគ្រប់គ្រាន់សម្រាប់ប្រើប្រាស់នៅឡើយ។

## ៣.២ ការប្រឈម

**កម្មវិធីទី១÷ ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត និងគមនាគមន៍**

- មិនទាន់មានលិខិតបទដ្ឋានគតិយុត្តដើម្បីគ្រប់គ្រងបទល្មើស នៃការដឹកជញ្ជូនលើសទម្ងន់លើផ្លូវជនបទ និងសម្រាប់ការគ្រប់គ្រងដីចំណីផ្លូវជនបទ
- ការចំណាយលើការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្តនិងគមនាគមន៍កាន់តែកើនឡើងខ្ពស់ដោយសារកំណើនតម្លៃវត្ថុធាតុដើម និងការដឹកជញ្ជូនឆ្ងាយ
- គុណភាពផ្លូវជនបទទទួលរងផលប៉ះពាល់ដោយសារការចាក់ដីលុបបំបាត់ប្រព័ន្ធបង្ហូរទឹក ។

**កម្មវិធីទី២÷ការកែលម្អលក្ខខណ្ឌនៃការរស់នៅរបស់សហគមន៍ជនបទ**

- ធនធានសម្រាប់គាំទ្រសកម្មភាពផ្គត់ផ្គង់ទឹកស្អាត និងលើកកម្ពស់អនាម័យជនបទមិនទាន់ឆ្លើយទៅនឹងតម្រូវការជាក់ស្តែង
- កិច្ចសហការរបស់អង្គការ និងដៃគូអភិវឌ្ឍន៍លើការងារផ្គត់ផ្គង់ទឹកជនបទនៅមានកម្រិត
- ការចាត់អាទិភាពការងារផ្គត់ផ្គង់ទឹក និងអនាម័យរបស់រដ្ឋបាលឃុំ- សង្កាត់ នៅមានកម្រិត
- សម្ភារផ្សព្វផ្សាយលើកកម្ពស់អនាម័យ និងទឹកស្អាតមិនទាន់ឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែង
- ការផ្សព្វផ្សាយអំពីការផឹកទឹកសុវត្ថិភាព និងអនាម័យល្អសម្រាប់តំបន់ដាច់ស្រយាល និងតំបន់បរិស្ថានប្រឈមនៅមិនទាន់បានទូលំទូលាយនៅឡើយ។

**កម្មវិធីទី៣÷ ការធ្វើពិពិធកម្មសកម្មភាពសេដ្ឋកិច្ចជនបទ**

- ការពង្រឹងសមត្ថភាព និងបណ្តុះបណ្តាលគណៈកម្មាធិការអភិវឌ្ឍន៍ភូមិនៅមានកម្រិត
- ការជំរុញចលនា និងសកម្មភាពអភិវឌ្ឍភូមិគំរូជនបទនៅមានកម្រិត
- កិច្ចសហប្រតិបត្តិការ និងដៃគូអភិវឌ្ឍន៍លើការងារពិពិធកម្មសេដ្ឋកិច្ចជនបទនៅមានកម្រិត
- ការចូលរួមអនុវត្តនីតិវិធីរបស់អាជ្ញាធរមូលដ្ឋាន និងស្ថាប័នពាក់ព័ន្ធក្នុងដំណើរការទទួលស្គាល់អត្តសញ្ញាណសហគមន៍ជនជាតិដើមភាគតិចនៅមានកម្រិត
- ពុំទាន់មានបញ្ជីមុខរបរនៅតំបន់ជនបទ។

**កម្មវិធីទី៤÷ ការពង្រឹងសេវាគាំទ្ររដ្ឋបាល និងកិច្ចការទូទៅ**

- ការពង្រឹងគុណភាពប្រព័ន្ធគ្រប់គ្រងផែនការអភិវឌ្ឍន៍ជនបទនៅមានកម្រិត
- ការបង្កើនលទ្ធភាពចុះបំពេញការងារនៅតាមមន្ទីរាជធានី- ខេត្តនៅមានកម្រិត-
- កង្វះខាតមន្ត្រីបច្ចេកទេសលើផ្នែកគ្រប់គ្រងប្រព័ន្ធសុវត្ថិភាពបច្ចេកវិទ្យាព័ត៌មានវិទ្យា។

## ៤. វិធានការដោះស្រាយ

ដើម្បីដោះស្រាយរាល់បញ្ហា ការប្រឈមខាងលើ ក្រសួងក៏បានដាក់ចេញនូវវិធានការដោះស្រាយ ដូចជា ១. រៀបចំគោលនយោបាយជាតិអភិវឌ្ឍន៍ជនបទ ឆ្នាំ២០២៥-២០៣៨ ឱ្យបានឆាប់ ២. ធ្វើការកែសម្រួលយុទ្ធសាស្រ្តក៏ដូចជាកម្មវិធីពីចំនួន ៤ មកជាចំនួន ៥ ដើម្បីស្របតាមយុទ្ធសាស្រ្តបញ្ចកោណ ដំណាក់កាលទី១ របស់រាជរដ្ឋាភិបាលកម្ពុជា បានដាក់ចេញនូវសកម្មភាពការងារតាមកម្មវិធីអាទិភាពជាទិសដៅបន្តសម្រាប់អនុវត្តនៅឆ្នាំ២០២៥ ដោយមានចំនួនកម្មវិធី ៥ អនុកម្មវិធីចំនួន ៣១ និងចង្កោមសកម្មភាពចំនួន២៣៤ មន្ទី ១០៩ ក្នុងនោះក្រសួងមានចំនួន)រាជធានី១២៥ ខេត្តមានចំនួន-), ៣. កំណត់វិធានការចំពោះបទល្មើសដឹកលើសទម្ងន់លើផ្លូវជនបទ, ៤. បន្តជំរុញឱ្យមានការផ្លាស់ប្តូរឥរិយាបថរស់នៅរបស់ប្រជាជននៅជនបទដាច់ស្រយាលឱ្យចេះរស់នៅស្អាត មានទឹកស្អាតបរិភោគ មានបង្គន់អនាម័យគ្រប់ផ្ទះ បរិភោគអាហារមានអនាម័យត្រឹមត្រូវ និងរស់នៅក្នុងបរិស្ថានស្អាត តាមរយៈការជំរុញឱ្យមានភូមិដែលឈប់បន្ទោរបង់ពាសវាលពាសកាល (ODF ឬ ODF Plus) កាន់តែច្រើនឡើង និង៥. ជួយពង្រឹងការយល់ដឹងពីគ្រោះមហន្តរាយ ដែលទទួលរងនូវផលប៉ះពាល់ជាញឹកញាប់កើតឡើងចំពោះស្រ្តី និងក្មេងស្រី និងបន្តជំរុញការសិក្សាស្រាវជ្រាវ វាយតម្លៃអត្តសញ្ញាណ វប្បធម៌ ទំនៀមទម្លាប់ ប្រពៃណីជនជាតិដើមភាគតិច ជាពិសេសការអភិវឌ្ឍជូនពួកគាត់ ដូចជាធ្វើផ្លូវ ផ្តល់កម្មវិធីទឹកស្អាត សេវាអនាម័យ ព្រមទាំងបណ្តុះបណ្តាលជំនាញផ្សេងៗ។

## ៥. ទិសដៅការងារបន្ត

ផ្អែកលើគោលនយោបាយ បណ្តាបញ្ហា និងការប្រឈមខាងលើ ក្រសួងអភិវឌ្ឍន៍ជនបទ បានដាក់ចេញនូវសកម្មភាពការងារតាមកម្មវិធីអាទិភាព ជាទិសដៅបន្តសម្រាប់អនុវត្តនៅឆ្នាំ២០២៥ ដូចតទៅ÷

### ៥.១. អភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត និងគមនាគមន៍ជនបទប្រកបដោយភាពធន់

- ការជួសជុល និងរក្សាគុណភាពផ្លូវជនបទ
- ការពង្រីកវិសាលភាពនៃការស្ថាបនា លើកកម្រិតហេដ្ឋារចនាសម្ព័ន្ធផ្លូវជនបទ
- ការរៀបចំបញ្ជីសារពើភ័ណ្ឌ និងមូលដ្ឋានទិន្នន័យផ្លូវជនបទតាមប្រព័ន្ធព័ត៌មានវិទ្យា
- ការសិក្សាស្រាវជ្រាវបច្ចេកវិទ្យាប្រកបដោយភាពធន់
- ការត្រួតពិនិត្យគុណភាព និងសុវត្ថិភាពផ្លូវជនបទ
- ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត និងគមនាគមន៍ជនបទប្រកបដោយភាពធន់ ដោយមន្ទីរជំនាញទាំង២៥។

### ៥.២. ការលើកកម្ពស់ការទទួលបានទឹកស្អាត និងអនាម័យបរិស្ថានជនបទ

- ការស្ថាបនាហេដ្ឋារចនាសម្ព័ន្ធទឹកស្អាតជនបទ
- ការបង្កើនប្រសិទ្ធភាពនៃការប្រើប្រាស់ទឹកស្អាតជនបទ
- ការស្ថាបនាហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្តអនាម័យជនបទ
- ការលើកកម្ពស់ការរស់នៅស្អាត ការអប់រំសុខភាព និងអនាម័យជនបទ
- ការសិក្សាស្រាវជ្រាវបច្ចេកវិទ្យាទឹកស្អាត និងអនាម័យប្រកបដោយភាពធន់
- ការលើកកម្ពស់ការទទួលបានទឹកស្អាតនិងអនាម័យបរិស្ថានជនបទដោយមន្ទីរជំនាញទាំង២៥។

### ៥.៣. ការជំរុញអភិវឌ្ឍសហគមន៍ជនបទ និងចលនាភូមិគំរូ

- ការគាំទ្រប្រសិទ្ធភាពសកម្មភាពអភិវឌ្ឍន៍សហគមន៍ជនបទ
- ការលើកកម្ពស់គុណភាព គុណតម្លៃ និងនវានុវត្តន៍សហគមន៍ជនបទ
- ការបង្កើត និងគាំទ្រមជ្ឈមណ្ឌលអភិវឌ្ឍន៍សហគមន៍ជនបទ
- ការអភិវឌ្ឍបច្ចេកវិទ្យាឌីជីថលសហគមន៍ជនបទ
- ការអភិរក្សជនជាតិដើមភាគតិច
- ការអភិវឌ្ឍជនជាតិដើមភាគតិច
- ការជំរុញអភិវឌ្ឍសហគមន៍ជនបទ និងចលនាភូមិគំរូ ដោយមន្ទីរជំនាញទាំង២៥។

### ៥.៤. ការលើកម្ពស់ការធ្វើពិពិធកម្មសេដ្ឋកិច្ចជនបទ

- ការជំរុញបង្កើតការងារ និងមុខរបរនៅជនបទ
- ការជំរុញសកម្មភាពសេដ្ឋកិច្ចគ្រួសារ និងទីផ្សារនៅជនបទ
- ការបណ្តុះបណ្តាលធនធានមនុស្ស និងជំនាញអាជីព
- ការបង្កើត និងគាំទ្រមជ្ឈមណ្ឌលអភិវឌ្ឍន៍ជនបទ
- ការបង្កើតនិងគាំទ្រវិទ្យាស្ថានជាតិអភិវឌ្ឍន៍ជនបទតាមភូមិភាគ
- ការលើកកម្ពស់ការធ្វើពិពិធកម្មសេដ្ឋកិច្ចជនបទ ដោយមន្ទីរជំនាញទាំង២៥។

### ៥.៥. ការគ្រប់គ្រងស្ថាប័ន និងសេវាគាំទ្រទូទៅ

- ការពង្រឹងគុណភាពប្រព័ន្ធគ្រប់គ្រងផែនការអភិវឌ្ឍន៍ជនបទ
- ការបង្កើនប្រសិទ្ធភាពនៃការប្រើប្រាស់ថវិកាកម្មវិធី
- ការបង្កើនប្រសិទ្ធភាពសវនកម្មផ្ទៃក្នុង និងអធិការកិច្ច
- ការពង្រឹងប្រសិទ្ធភាពគ្រប់គ្រងរដ្ឋបាល បរិវត្តកម្មឌីជីថល និងយេនឌ័រ
- សេវាគាំទ្រគោលនយោបាយ
- ការគ្រប់គ្រងស្ថាប័ន និងសេវាគាំទ្រទូទៅ ដោយមន្ទីរជំនាញទាំង២៥។

## ៦. សេចក្តីសន្និដ្ឋាន

រាជរដ្ឋាភិបាលកម្ពុជា ក្រោមការដឹកនាំប្រកបដោយឈ្លាសវៃ ប៉ិនប្រសព្វរបស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** បាននាំមកនូវកំណើនសេដ្ឋកិច្ច **៥,៨%** ក្នុងឆ្នាំ២០២៤នេះ ទោះបីស្ថិតក្នុងបរិបទនៃវិបត្តិសកលជាបន្តបន្ទាប់ក៏ដោយ។ ភាពជោគជ័យដ៏ត្រចះត្រចង់នេះ គឺកើតចេញពីកត្តាសុខសន្តិភាព ស្ថិរភាពនយោបាយក្នុងប្រទេស គួបផ្សំនឹងមានភាពស៊ាំជំងឺកូវីដ-១៩ ផងដែរ តាមរយៈយុទ្ធនាការចាក់វ៉ាក់សាំងដ៏សកម្មបំផុតនៅទូទាំងប្រទេសនាពេលកន្លងមក ដែលបានបង្កលក្ខណៈឱ្យប្រជាជនទទួលបាននូវការលើកកម្ពស់កម្រិតជីវភាព សុខុមាលភាព គុណតម្លៃនៃជីវិតរស់នៅ និងការអប់រំសីលធម៌សង្គមរបស់ប្រជាជនជនបទ ។

សម្រាប់ឆ្នាំ២០២៤នេះ ជារួម ក្រសួងបានអនុវត្តសកម្មភាពតាមរយៈកម្មវិធីអាទិភាពទាំង ៤ ខាងលើសម្រេចបានលទ្ធផលជាសារវ័ន្ត តាមរយៈការធ្វើសមាមាត្រនៃលទ្ធផលឆ្លុះបញ្ចាំងជាមួយសូចនាករ

និងគោលដៅសមិទ្ធកម្ម ដែលបានកំណត់ក្នុងឆ្នាំ២០២៤ ក្នុងនោះមានការអនុវត្តការចំណាយថវិកា ចំនួន **៩១%** សម្រេចគោលដៅបានចំនួន **៩៨%** ដូចខាងក្រោម÷

| | | | |
|---|---|---|---|
| កម្មវិធីទី១ | ÷ | ប្រើប្រាស់ថវិកា ចំនួន ៩០% | សម្រេចគោលដៅ បានចំនួន ៩៧% |
| កម្មវិធីទី២ | ÷ | ប្រើប្រាស់ថវិកា ចំនួន ៩៦% | សម្រេចគោលដៅ បានចំនួន ៩៧% |
| កម្មវិធីទី៣ | ÷ | ប្រើប្រាស់ថវិកា ចំនួន ៨៩% | សម្រេចគោលដៅ បានចំនួន ៩៨% |
| កម្មវិធីទី៤ | ÷ | ប្រើប្រាស់ថវិកា ចំនួន ៩៣% | សម្រេចគោលដៅ បានចំនួន ៩៨%។ |

ផ្អែកលើលទ្ធផលជាស្នាដៃដ៏ធំធេងខាងលើ និងដោយមានកត្តារួមផ្សំជាច្រើន នៅឆ្នាំ២០២៥ ខាងមុខនេះ ក្រសួងអភិវឌ្ឍន៍ជនបទនឹងរៀបចំអនុវត្តនូវរចនាសម្ព័ន្ធកម្មវិធីថ្មីចំនួន ៥ សម្រាប់នីតិកាលទី៧ ឱ្យស្របទៅនឹងកម្មវិធីនយោបាយ យុទ្ធសាស្ត្រ ដ៏ត្រឹមត្រូវ ច្បាស់លាស់ និងឆ្លើយតបឱ្យចំគោលដៅទៅនឹងសំណូមពររបស់ប្រជាពលរដ្ឋ ព្រមទាំងលើកកម្ពស់ឧត្តមប្រយោជន៍ជាតិ ដើម្បីបន្តបេសកកម្មរបស់ខ្លួន ក្នុងការរួមចំណែកកាត់បន្ថយភាពក្រីក្រ និងប្រែក្លាយប្រទេសកម្ពុជា ជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងជាប្រទេសមានចំណូលខ្ពស់នៅឆ្នាំ២០៥០។ កម្មវិធីថ្មីទាំង ៥ ដែលនឹងត្រូវអនុវត្តនៅក្នុងឆ្នាំ២០២៥ ខាងមុខនេះ រួមមាន÷

| | | |
|---|---|---|
| កម្មវិធីទី១ | ÷ | អភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត និងគមនាគមន៍ប្រកបដោយភាពធន់ |
| កម្មវិធីទី២ | ÷ | លើកកម្ពស់ការទទួលបានទឹកស្អាត និងអនាម័យបរិស្ថានជនបទ |
| កម្មវិធីទី៣ | ÷ | ជំរុញអភិវឌ្ឍសហគមន៍ជនបទ និងចលនាភូមិគំរូ |
| កម្មវិធីទី៤ | ÷ | លើកកម្ពស់ការធ្វើពិពិធកម្មសេដ្ឋកិច្ចជនបទ |
| កម្មវិធីទី៥ | ÷ | ការគ្រប់គ្រងស្ថាប័ន និងសេវាគាំទ្រទូទៅ។ |

**រដ្ឋមន្ត្រី**